ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ

វិទ្យាល័យ ហ៊ុន សែន បាត់ដឹង

អបអរសាទរទិវាជាតិអំណាន លើកទី៧

១១ មីនា ២០២២

# សិក្ខាកថាក្រោមប្រធានបទ

# «តួនាទីអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ»

ដោយ មី សុវណ្ណា

ព.ស. ២៥៦៥ គ.ស. ២០២២

# ប្រវត្តិរូបសង្ខេបបេក្ខជន

## ព័ត៌មានទូទៅ

- ឈ្មោះ : មី សុវណ្ណ
- ភេទ : ប្រុស
- ថ្ងៃ ខែ ឆ្នាំកំណើត : ១៦ ធ្នូ ១៩៩០
- ទីកន្លែងកំណើត : ភូមិក្រាំងពញ្ញា ឃុំវាលពង់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ
- ទីលំនៅបច្ចុប្បន្ន : ភូមិដំណាក់ស្នាច់ ឃុំវាលពង់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ
- កម្រិតជំនាញ : មធ្យមសិក្សាទុតិយភូមិ
- ថ្ងៃ ខែ ឆ្នាំចូលបម្រើការងារ : ០១-១០-២០១៤

## ការសិក្សា

- ២០០៧-២០០៩ : មធ្យមសិក្សាទុតិយភូមិ (វិទ្យាល័យឧដុង្គ កំពង់ស្ពឺ)
- ២០០៩-២០១៣ : បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ (សាកលវិទ្យាល័យភូមិន្ទភ្នំពេញ)
- ២០១៣-២០១៧ : បរិញ្ញាបត្រជាន់ខ្ពស់ភាសាវិទ្យា (សាកលវិទ្យាល័យភូមិន្ទភ្នំពេញ)
- ២០១២-២០១៤ : គរុសិស្សភាសាបារាំង-ខ្មែរ (វិទ្យាស្ថានជាតិអប់រំ)
- ២០១៧-២០១៨ : គរុនិស្សិតកម្រិតឧត្តម អក្សរសាស្ត្រខ្មែរ (វិទ្យាស្ថានជាតិអប់រំ)
- ២០០៩ ជាអតីតជ័យលាភីសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ខ្មែរ ឆ្នាំ២០០៩

## អត្តភាពការងារ

- ឆ្នាំ២០១៤- បច្ចុប្បន្ន គ្រូអក្សរសាស្ត្រខ្មែរវិទ្យាល័យ ហ៊ុន សែន បាត់ដឹង

## ទំនាក់ទំនងបេក្ខជន


- ទូរស័ព្ទទាក់ទង : ០១៧ ៤២៤ ២៦៣
- តេឡេក្រាម : ០១៥ ៤០៤ ៤៨៣
- អ៊ីម៉ែល : sovannbandit@gmail.com

# មាតិកា

I- សេចក្តីផ្តើម....................................................................................................1

II- តួសេចក្តី........................................................................................................1

II.១- ពន្យល់បច្ចេកសព្ទ...........................................................................................1

II.១.១- បច្ចេកសព្ទ«អក្សរសិល្ប៍»..............................................................................1

II.១.២- បច្ចេកសព្ទ«ពុទ្ធនិយម»...............................................................................2

II.២- ពន្យល់ប្រធានបទ............................................................................................4

II.៣- បកស្រាយប្រធានបទ.......................................................................................5

II.៣.១- ទិដ្ឋភាពប្រវត្តិសាស្ត្រនៅសម័យកណ្តាល......................................................5

II.៣.២- ទិដ្ឋភាពព្រះពុទ្ធសាសនាថេរវាទនៅសម័យកណ្តាល......................................10

II.៣.៣- តួនាទីអក្សរសិល្ប៍ពុទ្ធនិយមសម័យក្រោយអង្គរ...........................................12

II.៣.៣.១- តួនាទីអក្សរសិល្ប៍ពុទ្ធនិយម និងការបណ្តុះបញ្ញាពុទ្ធិ.................................12

II.៣.៣.២- តួនាទីអក្សរសិល្ប៍ពុទ្ធនិយម និងការអប់រំ...................................................14

II.៣.៣.៣- តួនាទីអក្សរសិល្ប៍ពុទ្ធនិយម និងការបណ្តុះសោភ័ណជីវិត..............................17

II.៣.៣.៤- តួនាទីអក្សរសិល្ប៍ពុទ្ធនិយម និងការចូលរួមអភិវឌ្ឍសង្គម............................18

II.៣.៣.៥- តួនាទីអក្សរសិល្ប៍ពុទ្ធនិយម និងបញ្ហានយោបាយ.......................................20

II.៣.៣.៦- តួនាទីអក្សរសិល្ប៍ពុទ្ធនិយម និងការព្យាបាលផ្លូវចិត្ត.....................................21

II.៣.៣.៧- តួនាទីអក្សរសិល្ប៍ពុទ្ធនិយម និងវប្បធម៌....................................................23

II.៣.៣.៨- តួនាទីអក្សរសិល្ប៍ពុទ្ធនិយម និងព្រលឹងជាតិខ្មែរ.........................................24

II.៣.៣.៩- តួនាទីអក្សរសិល្ប៍ពុទ្ធនិយម និងការបណ្តុះគំនិតវិទ្យាសាស្ត្រ.......................................26

II.៣.៣.១០- តួនាទីអក្សរសិល្ប៍ពុទ្ធនិយម និងសន្តិភាពផ្លូវចិត្ត (សីល សមាធិ បញ្ញា).....................27

II.៤- សរុបខ្លឹមសារ.........................................................................................................28

III-បញ្ចប់សេចក្តី............................................................................................................29

ឯកសារពិគ្រោះ

ឧបសម្ព័ន្ធ

# ប្រធានបទ៖ «តួនាទីអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ»

## សេចក្តីអធិប្បាយ

## I- សេចក្តីផ្តើម

ប្រទេសកម្ពុជាបានឆ្លងកាត់របបនៃការដឹកនាំសង្គមជាច្រើនសម័យកាលមកហើយ ។ ក្នុងនោះផងដែរ យើងសង្កេតឃើញថាព្រះរាជាណាចក្រមួយនេះបានផ្លាស់ប្តូររបបសង្គមរបស់ខ្លួនស្របទៅតាមបរិបទជាក់ស្តែង ។ តាំងពីសម័យមុនអង្គរ សម័យអង្គរ និងសម័យក្រោយអង្គរ តួនាទីអក្សរសិល្ប៍ពិតជាបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងសង្គមខ្មែរយើង។ ដោយឡែកនៅសម័យក្រោយអង្គរ ស្នាដៃអក្សរសិល្ប៍ខ្មែរនៅតែត្រូវបាននិពន្ធតាក់តែងឡើងស្របទៅតាមសង្គមបរិបទជាក់ស្តែងនៃសង្គមខ្មែរ។ កវីនិពន្ធខ្មែរភាគច្រើនជាគ្រហស្ថសុទ្ធសឹងតែធ្លាប់បួសរៀន ឬជាព្រះសង្ឃ ជាព្រះគ្រូចៅអធិការ និងមានចំណេះដឹងយល់ជ្រួតជ្រាបជ្រៅជ្រះទ្រឹស្តីព្រះពុទ្ធសាសនា ហើយតាក់តែងជាកំណាព្យបទផ្សេងៗទៅតាមទេពកោសល្យរបស់ខ្លួន។ វិធីនិម្មិតកម្មស្នាដៃអក្សរសិល្ប៍ទាំងអស់នោះច្រើនបង្កប់នូវទស្សនៈកម្មផលដែលមានទំនោរទៅរកព្រះពុទ្ធសាសនាជាជាងឆ្លុះបញ្ចាំងពីតថភាពសង្គមជាក់ស្តែងរបស់សង្គមខ្មែរ ហើយដែលយើងហៅស្នាដៃទាំងនោះថាជាអក្សរសិល្ប៍ពុទ្ធនិយម។ ទោះបីជាស្នាដៃទាំងនោះមានចរិតលក្ខណៈបែបណាក៏ដោយ ប៉ុន្តែស្នាដៃកវីនិពន្ធទាំងឡាយសុទ្ធសឹងតែជាស្នាដៃដែលបានបម្រើសង្គមខ្មែរ ចំណង់ចំណូលចិត្តមនុស្សខ្មែរ និងឆ្លាក់ជាប់នៅក្នុងក្រអៅបេះដូងមនុស្សខ្មែរពិតៗនាសម័យក្រោយអង្គរ។

តើអក្សរសិល្ប៍ពុទ្ធនិយមបានដើរតួនាទីយ៉ាងដូចម្តេចខ្លះនៅសម័យក្រោយអង្គរ ?

## II-តួសេចក្តី

### II.១- ពន្យល់បច្ចេកសព្ទ

#### II.១.១- បច្ចេកសព្ទ«អក្សរសិល្ប៍»

បើតាមវចនានុក្រមខ្មែរបានផ្តល់និយមន័យចំពោះពាក្យ «អក្សរ» និង«សិល្ប៍» ជាមុនថា អក្សរ (ន.)(សំ.បា.)អក្ខរៈ។ រីឯសិល្ប៍ (ន) (សំ.បា. សិប្បៈ) សិប្បៈ។ ហេតុនេះគេអាចទាញបានថា «អក្សរសិល្ប៍»ជាសិល្បៈនៃការប្រើប្រាស់តួអក្សរដើម្បីបង្កើតទៅជាសាច់រឿង។

លោក ពៅ សាមី «អក្សរសិល្ប៍» មានន័យថាវិទ្យាស្យង់ដែលលើកយកបញ្ហាមនុស្សមកចោទ និងដោះស្រាយដោយសិល្បវិធីតាមសម័យកាលនីមួយៗ។

តាមលោក កេង វ៉ាន់សាក់ «អក្សរសិល្ប៍»គឺជាវិទ្យាសាស្ត្រដែលលើកយកបញ្ហាមនុស្សមកចោទ និងដោះស្រាយដោយសិល្បវិធីតាមសម័យកាលនីមួយៗ។

លោក ម៉ាស៊ីម គ័រគី បានផ្តល់និយមន័យចំពោះអក្សរសិល្ប៍ថា«អក្សរសិល្ប៍ជាការសិក្សាពីមនុស្ស»។

លោក ធ សោ «អក្សរសិល្ប៍ជាវិទ្យាសាស្ត្រមួយសិក្សាពីមនុស្សដោយលើកយកបញ្ហាមនុស្សមកចោទ និងដោះស្រាយតាមសិល្ប៍រូបារម្មណ៍»។

ស្តង់ដាល់ «អក្សរសិល្ប៍គឺជាកញ្ចក់ដែលគេដាក់តាមដងផ្លូវ»។ ពំនោលនេះបានន័យសេចក្តីថា អក្សរសិល្ប៍បានឆ្លុះបញ្ចាំងឱ្យឃើញនូវរាល់សកម្មភាពទាំងឡាយដែលបានឆ្លងកាត់វា។

អក្សរសិល្ប៍ជាសិល្បៈនៃការប្រើប្រាស់តួអក្សរប្រកបទៅដោយសិល្បៈក្នុងការសម្តែងនូវអារម្មណ៍ ចិត្តគំនិតព្រលឹងស្មារតី។

សរុបមក អក្សសិល្ប៍ជាកញ្ចក់ឆ្លុះបញ្ចាំងពីតថភាពសង្គមពិតៗ ហើយដែលបានបកស្រាយពីអ្វីដែលបានកើតឡើងស្របតាមព្រឹត្តិការណ៍របស់មនុស្ស។ មនុស្សជាអ្នកបង្កើតនូវប្រវត្តិសាស្ត្រជីវិតរបស់ខ្លួនពីសម័យកាលមួយមកដល់សម័យកាលមួយទៀត។ ដូច្នេះដើម្បីឱ្យជីវិតមានភាពប្រសើរជឿនលឿនទៅមុខគឺមនុស្សទាមទារជាចាំបាច់ដើម្បីកត់ត្រារាល់អ្វីៗដែលខ្លួនបានជួបប្រទះជាសាក្សីសង្គម និងជាតឹកតាងសម្រាប់មនុស្សជំនាន់ក្រោយ។

### II.១.២- បច្ចេកសព្ទ«ពុទ្ធនិយម»

អក្សរសិល្ប៍ពុទ្ធនិយម គឺជាស្នាដៃអក្សរសិល្ប៍ទាំងឡាយណាដែលបានទទួលឥទ្ធិពលពីព្រះពុទ្ធសាសនា។ ក្នុងនោះផ្តោតសំខាន់ទៅលើបញ្ហាកម្មផលជាចម្បងបានសេចក្តីថា កម្មល្អឱ្យផលល្អ កម្មអាក្រក់ឱ្យផលអាក្រក់ ហើយអំពើល្អ និងអំពើអាក្រក់មិនអាចសងគ្នារួចបានឡើយ ។ ជាការពិតណាស់ថា តាមទ្រឹស្តីព្រះពុទ្ធសាសនាបានចែងយ៉ាងច្បាស់ថា ធម៌សឱ្យផលស ធម៌ខ្មៅឱ្យផលខ្មៅ។ បើអ្នកសាបព្រោះអ្វីអ្នកនឹងទទួលបានផលហ្នឹងមកវិញ។ អ្នកព្រះភិរម្យភាសាអ៊ូ ហៅង៉ុយ ឬកវីង៉ុយក៏ធ្លាប់បានពោលដែរថា ដើមក្រូចផ្លែក្រូច ដើមស្វាយផ្លែស្វាយ ។ បើអ្នកសាបព្រោះខ្យល់ អ្នកនឹងទទួលបានខ្យល់ ហើយបើអ្នកសាបព្រោះនូវព្យុះសង្ឃរា អ្នកនឹងទទួលបានមកវិញជាព្យុះសង្ឃរាជាក់ជាមិនខាន។

អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមចែកជាបីប្រភេទ គឺអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធ អក្សរសិល្ប៍ពុទ្ធនិយមក្លាយ និងអក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ(ផ្លម)។ អក្សរសិល្ប៍ទាំងបីប្រភេទដែលគេកំណត់ហៅឈ្មោះនេះ ដោយគេសម្គាល់លើខ្លឹមសារនៃរឿងដែលបង្ហាញពីឥទ្ធិពលព្រះពុទ្ធសាសនាតិច ឬច្រើនតាមរយៈការពិពណ៌នារបស់អ្នកនិពន្ធនៅក្នុងរឿងនីមួយៗសម្គាល់លើប្រភព និងអត្តរូបនៃរឿង។

អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធជារឿងដែលទទួលឥទ្ធិពលខ្លាំងបំផុតពីព្រះពុទ្ធសាសនា ហើយសំដៅយករឿងទាំងដប់ ដែលថ្លែងពីអតីតប្រវត្តិរបស់ព្រះសក្យមុនីគោតមបរមសម្ពុទ្ធក្នុងដប់ព្រះជាតិ មុនព្រះជាតិដែលបានត្រាស់ដឹង។ រឿងទាំងដប់នោះសម្គាល់លើរឿងក្នុងស្នាដៃទសជាតកដែលគេចាត់ទុកជាគម្ពីរដ៏សំខាន់នៃលទ្ធិព្រះពុទ្ធសាសនា ព្រោះរឿងទាំងដប់នៃទសជាតកនេះមាននៅក្នុងសុត្តន្តបិដក ខុទ្ទកនិកាយជាតក ហើយបានលើកឡើងពីការតស៊ូរបស់ព្រះសម្មាសម្ពុទ្ធក្នុងពេលដែលព្រះអង្គយោនយកកំណើតជាតួអង្គពោធិសត្វក្នុងជាតិផ្សេងៗក្នុងការបំពេញបារមីដើម្បីបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ។

អក្សរសិល្ប៍ពុទ្ធនិយមក្លាយជារឿងដែលទទួលឥទ្ធិពលព្រះពុទ្ធសាសនាច្រើនបង្គួរដែរ តែឈ្មោះរឿងទាំងនោះមិនមាននៅក្នុងសុត្តន្តបិដក ខុទ្ទកនិកាយជាតកទាំងអស់ទេ មានមួយចំនួនតូចប៉ុណ្ណោះ។ រឿងខ្លះមានចំណងជើងរឿងដូចគ្នាទៅនឹងចំណងជើងជាតកនៅក្នុងសុត្តន្តបិដក ខុទ្ទកនិកាយជាតក តែខ្លឹមសាររឿងខុសគ្នាដោយអន្លើ រឿងមួយចំនួនទៀត ចំណងជើងរឿងខុសគ្នា តែខ្លឹមសាររឿងប្រហាក់ប្រហែលគ្នា។ រឿងមួយទៀត ចំណងរឿងក៏ដូចគ្នា និងខ្លឹមសាររឿងក៏ដូចគ្នា។ អក្សរសិល្ប៍ពុទ្ធនិយមក្លាយនេះសំដៅយករឿងទាំងហាសិបក្នុងបញ្ញាសជាតក។ តួអង្គនៅក្នុងរឿងអក្សរសិល្ប៍ពុទ្ធនិយមក្លាយនេះមិនមែនជាតួអង្គព្រះពោធិសត្វ ដែលខំបំពេញបារមីដើម្បីត្រាស់ជាព្រះពុទ្ធនោះឡើយគឺគ្រាន់ជាតួអង្គពោធិសត្វដែលខំកសាងអំពើជាកុសលផ្សេងៗជាដើម។

អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ ឬហៅពុទ្ធនិយមផ្លមជាស្នាដៃអក្សរសិល្ប៍មួយបែបដែលពុំមែនជារឿងទសជាតក និងពុំមែនជារឿងបញ្ញាសជាតក។ វាជាស្នាដៃអក្សរសិល្ប៍ខ្មែរដែលកើតឡើងនៅសម័យកណ្តាល (លង្វែកនិងឧដុង្គ) ហើយទទួលឥទ្ធិពលពីលទ្ធិព្រះពុទ្ធសាសនាដែរ។ អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុនេះ ជាស្នាដៃរឿងនិពន្ធជាពាក្យកាព្យដោយករីបណ្ឌិតខ្មែរក្នុងសម័យកណ្តាលពិសេសក្នុងសតវត្សរ៍ទី១៧-១៩។ គេហៅស្នាដៃប្រភេទនេះថាជា រឿងល្បែង ឬសាស្ត្រាល្បែងក៏បានដែរ។

## II.១.៣- អក្សរសិល្ប៍ក្រោយសម័យអង្គរ

សម័យក្រោយអង្គរ អក្សរសិល្ប៍ខ្មែរត្រូវបានចែកចេញជាពីរដំណាក់កាលៈ

- អក្សរសិល្ប៍ក្នុងដំណាក់កាលសម័យលង្វែក (ចាប់ពីសតវត្សទី១៥ ដល់ដើមសតវត្សទី១៧)
- អក្សរសិល្ប៍ក្នុងដំណាក់កាលសម័យឧត្តុង្គ (ចាប់ពីសតវត្សទី១៧ ដល់សតវត្សទី១៩)

ក្នុងដំណាក់កាលសម័យលង្វែក អក្សរសិល្ប៍ពុំសូវមានការរីកចម្រើនទេ។ គេសង្កេតឃើញស្នាដៃអក្សរសិល្ប៍តិចណាស់ស្ទើរតែគ្មាន។ ការមិនរីកចម្រើនអាស្រ័យដោយស្ថានភាពចុះដុនដាបទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ និងវប្បធម៌ដែលបណ្ដាលមកពីសង្គ្រាមផ្ទៃក្នុង និងវប្បធម៌ការត្បាតរបស់ជនជាតិបរទេស (ថៃ ឬសៀម)។ មិនតែប៉ុណ្ណោះក្រោយឈ្នះសង្គ្រាម គេបានយកក្បួនគម្ពីសំខាន់ៗរបស់ជាតិយកទៅប្រទេសរបស់គេថែមទៀត ដែលធ្វើឱ្យខ្មែរយើងអស់មូលដ្ឋានរបស់ខ្លួនក្នុងការកសាងវិស័យអក្សរសាស្ត្រ-អក្សរសិល្ប៍នេះឯង ។

ក្នុងដំណាក់កាលសម័យឧត្តុង្គ ចាប់ពីសតវត្សទី១៧មក អក្សរសិល្ប៍បានចាប់កសាង និងរីកចម្រើនឡើងវិញ។ នាពេលនោះ គេឈប់ចារឹកលើថ្មទៀតហើយ គេចាប់ផ្ដើមសរសេរលើសាស្ត្រាស្លឹករឹតនិងនៅលើក្រាំង។ អត្ថន័យនៃអក្សរសិល្ប៍នៅក្នុងសម័យនេះច្រើនមានទំនោរទៅរកព្រះពុទ្ធសាសនាបែបហីនយាន។ ព្រហ្មញ្ញសាសនា និងពុទ្ធសាសនាមហាយានបានរីកដុះដាលនៅក្នុងសម័យអង្គរ ហើយបានចុះអានុភាពបន្តិចម្ដងៗតាំងពីចុងសម័យអង្គរ និងបានរលាយខ្លួនបន្តិចម្ដងៗនៅក្នុងសម័យឧដុង្គនេះ។ តែទោះបីយ៉ាងដូចនេះក៏ដោយក៏ឥទ្ធិពលខ្លះនៃព្រហ្មញ្ញសាសនា និងពុទ្ធសាសនាមហាយាននៅតែមានទោះបីតិច ឬច្រើនក្ដី។ អាស្រ័យហេតុនេះ ទើបស្នាដៃអក្សរសិល្ប៍នៅសម័យនេះ មានទំនាក់ទំនងទៅរកពុទ្ធសាសនា តែក៏នៅមានលាយឡំបែបព្រាហ្មណ៍និយមខ្លះ និងមានលក្ខណៈអច្ឆរិយៈលាយឡំផងដែរ។

## II.២- ពន្យល់ប្រធានបទ

ស្របតាមការពន្យល់បញ្ញត្តិខាងលើនេះ ប្រធានបទទាំងមូលចង់ឱ្យស្មេរធ្វើការស្រាយបំភ្លឺពីតួនាទីចម្បងនៃស្នាដៃអក្សរសិល្ប៍ខ្មែរដែលមានទំនោរទៅលើព្រះពុទ្ធសាសនានាសម័យក្រោយអង្គរនេះឯង។ សម័យក្រោយអង្គរនេះ យើងសូមកំណត់ថាជាសម័យកាលកណ្ដាលដែលយើងនឹងលើកយកសម័យកាលសំខាន់ពីរគឺ សម័យលង្វែក និងសម័យឧដុង្គ។ ប្រវត្តិសាស្ត្ររមែងជាប់ទាក់ទងយ៉ាងស្អិតរមួតជាមួយនឹង

ស្នាដៃអក្សរសិល្ប៍ខ្មែរ។ ដូចនេះដើម្បីស្វែងយល់ពីតួនាទីនៃអក្សរសិល្ប៍ពុទ្ធនិយមនាសម័យកណ្ដាលបាន លុះត្រាតែយើងស្វែងយល់ពីព្រឹត្តិការណ៍សង្គមសំខាន់ៗ ឬហេតុការណ៍ប្រវត្តិសាស្ត្រខ្លះនៃសម័យកាលនោះជាមុនសិន។ ពីព្រោះថាប្រវត្តិសាស្ត្រ និងអក្សរសិល្ប៍ប្រៀបបានដូចជាបងប្អូនភ្លោះដែលមិនអាចកាត់ផ្ដាច់ពីគ្នាឱ្យដាច់ស្រឡះបានឡើយ។ ត្រង់ន័យនេះ ការលើកឡើងលម្អិតពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៅសម័យកណ្ដាលគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការយល់ដឹងពីតួនាទីអក្សរសិល្ប៍ពុទ្ធនិយមនាសម័យក្រោយអង្គរ។

## II.៣- បកស្រាយប្រធានបទ

## II.៣.១- ទិដ្ឋភាពប្រវត្តិសាស្ត្រនៅសម័យកណ្ដាល

ដើម្បីសិក្សាស្វែងយល់ពីតួនាទីអក្សរសិល្ប៍នាសម័យក្រោយអង្គរ ជាដំបូងយើងគប្បីស្វែងយល់ពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនាសម័យកាលនោះជាមុនសិន។ នៅសម័យក្រោយអង្គរជាសម័យកាលមួយដែលប្រទេសកម្ពុជាកំពុងតែរីករវ និងញាំញីដោយភ្លើងសង្គ្រាម។ ប្រការទាំងអស់នេះច្រើនតែកើតឡើងដោយសារតែទំនាស់ផ្ទៃក្នុង និងបច្ចាមិត្រដែលបានប៉ងលេបត្របាក់យកទឹកដីខ្មែរ។ ត្រង់នេះ យើងសូមលើកយកនូវសម័យកាលពីរមកបង្ហាញគឺសម័យលង្វែក និងសម័យឧដុង្គ។

### ក. សម័យលង្វែកៈ

សម័យលង្វែកគឺជាសម័យក្រោយពីរជ្ជកាលព្រះបាទពញាយ៉ាត ប្រទេសកម្ពុជាកើតមានចម្បាំងជាច្រើនលើកច្រើនសា។ រាជធានីត្រូវបានផ្លាស់ប្ដូរជាច្រើនកន្លែងវិលចុះវិលឡើងពីក្រុងអង្គរ ទួលបាសាន្ត (កំពង់ចាម) ភ្នំពេញ (ចតុមុខ) លង្វែក (កំពង់ឆ្នាំង)។ ក្នុងរាជ្យព្រះអង្គចន្ទទី១ រាជធានីតាំងនៅក្រុងមានជ័យ ខេត្តពោធិ៍សាត់ រួចប្ដូរមកក្រុងលង្វែកវិញ។ ព្រះបាទចន្ទរាជា ឬព្រះអង្គចន្ទទី១ ជាអនុជពៅព្រះស្រីសុគន្ធបទ ឬជាបុត្រធម្មរាជា។ ពេលដែលស្ដេចកនធ្វើគុតស្រីសុគន្ធបទនៅបន្ទាយស្ទឹងសែននៅឆ្នាំ ១៥១២ ពញាចន្ទនៅក្រុងអយុធ្យានៅឡើយ។ ក្នុងពេលធ្វើសង្គ្រាមជាមួយស្ដេចកន មន្ត្រី និងរាស្ត្រសុំឱ្យព្រះអង្គចន្ទឡើងសោយរាជ្យ ទ្រង់ក៏យល់ព្រម។ ទ្រង់ជាស្ដេចមួយអង្គដ៏ល្បីល្បាញដែលបានរំដោះដីខ្មែរភាគខាងលិចពីសៀម។ ក្រៅពីបន្ទាយលង្វែក ទ្រង់បានកសាងវត្តអារាមជាច្រើននៅខែត្រពោធិ៍សាត់

បរិបូណ៌ ជួសជុលវត្តនៅឧដុង្គមានវត្តលើភ្នំរាជទ្រព្យជាដើម (ព្រះពុទ្ធរូបចូលព្រះនិព្វាន) វត្តត្រឡែងកែង នៅក្នុងបន្ទាយលង្វែកដែលស្ថិតនៅលើទួលមួយកន្លែង មានរាងជាជើងក្អែកក្នុងវិហារនេះតម្កល់ព្រះពុទ្ធរូបត្រឡែងកែងគឺព្រះពុទ្ធរូបបួនអង្គគង់ឈរទល់ព្រះខ្នងនឹងគ្នា ហើយបែរព្រះភក្ត្រទៅទិសទាំងបួន ហើយនឹងបានកសាងបដិមាត្រឡែងកែងរូបព្រះគោ។ ប្រមូលអ្នកប្រាជ្ញ បណ្ឌិត កវីអោយចងក្រង និងសរសេរគម្ពីរ ក្បួនច្បាប់គ្រប់ប្រភេទសម្រាប់កូនខ្មែរជំនាន់ក្រោយ។ តែគួរឱ្យស្តាយនៅឆ្នាំ១៥៦៦ ទ្រង់ក៏សោយទិវង្គត អង្ជិធាតុតម្កល់ទុកលើភ្នំព្រះរាជទ្រព្យ។

គ្រិស្តសករាជឆ្នាំ១៥៩៤ ក្រុងលង្វែកត្រូវពួកសៀមវាយយកបាន។ ស្តេចសៀមបានតែងតាំងមេទ័ពម្នាក់ឈ្មោះ ព្យាមហាមន្ត្រី ព្រមទាំងរក្សាទុកកងទ័ពពីរម៉ឺននាក់ឱ្យនៅត្រួតត្រាក្រុងលង្វែក។ ការបែកបាក់ក្រុងលង្វែកបានបង្កឱ្យមានការវិនាសនៃទ្រព្យសម្បត្តិជាច្រើន មន្ត្រីសេនាបតី អ្នកប្រាជ្ញ ព្រាហ្មណ៍ បុរោហិត អ្នកចេះដឹង គម្ពីរ ក្បួនច្បាប់ តម្រា និងវត្ថុមានតម្លៃជាច្រើនត្រូវបានសៀមប្រមូលទៅស្រុកវារាជវង្សានុវង្សខ្មែរជាច្រើនដែលក្នុងនោះឧបរាជ និងជាមេទ័ពខ្មែរមួយអង្គគឺព្រះបាទស្រីសុរិយោពណ៌ក៏ត្រូវសៀមនាំទៅស្រុកវាដែរ។ ការបែកបាក់នេះជាការធ្លាក់ចុះដ៏ធ្ងន់ធ្ងរនៃឥទ្ធិពលរបស់រាជាណាចក្រខ្មែរ ហើយបណ្តាលឱ្យមានការបែកបាក់សាមគ្គីក្នុងប្រទេសកើតឡើង។ ទោះជាយ៉ាងនេះក្តី ការត្រួតត្រារបស់មេទ័ពសៀមលើក្រុងលង្វែកមិនបានរយៈពេលយូរប៉ុន្មានឡើយ។ រាមាជើងព្រៃ (១៥៩៤ - ១៥៩៦) ដែលជាញាតិវង្សម្នាក់បានលើកទ័ពទៅវាយឆ្មក់ ហើយសម្លាប់មេទ័ពសៀមនោះបាន ហើយឡើងសោយរាជ្យ។ ប៉ុន្តែការភ័យខ្លាចចំពោះកម្លាំងរបស់សៀមក្រែងវិលត្រឡប់មកវិញបានធ្វើឱ្យរាមាជើងព្រៃត្រូវបង្ខំចិត្តប្តូរទៅតាំងទីរាជវាំងនៅស្រីសន្ធរ (កំពង់ចាម) វិញ ដែលនៅទីនោះ ទ្រង់ត្រូវបានធ្វើគុតក្នុងពេលដែលទ្រង់ចេញទៅធ្វើការបង្ក្រាបជនជាតិអេស្ប៉ាញ ឈ្មោះ Ruiz និងជនជាតិប័ទុយកាល់ឈ្មោះ Veloso ។

ញាតិវង្សមួយអង្គទៀតឈ្មោះ ពញាតន់ ដែលជាអនុជរបស់ព្រះបាទជ័យជេដ្ឋាទី១ ត្រូវបានគេតែងតាំងអោយសោយរាជ្យពីឆ្នាំ ១៥៩៦-៩៧។ ស្តេចអង្គនេះបានតែងតាំង Beloso ឱ្យធ្វើជាស្តេចត្រាញ់លើដែនដីបាភ្នំទុកជាការសងគុណ។ ប៉ុន្តែនៅខេត្តត្បូងឃ្មុំការបះបោរមួយដែលដឹកនាំដោយប៉ោរាត

និងលក្ស៊ីណាបានកើតឡើង ។ ទ្រង់ដឹកនាំទ័ពទៅបង្ក្រាបពួកនេះ ប៉ុន្តែត្រូវពួកនេះធ្វើគុត ។

ពួកមន្ត្រីសេនាបតីក៏យាងពញាអនដែលជាព្រះបិតុលា (ពូ) របស់ពញាតន់ ឱ្យស្នងរាជ្យនៅឆ្នាំ ១៥៩៧ ។ ទ្រង់បានកម្ចាត់ ប៉ោរាត និងលក្ស៊ីណា ហើយនាំទ័ពត្រឡប់មកវិញបានពាក់កណ្តាលផ្លូវក៏បោះ

ជំរំសម្រាក។ នៅទីនោះទ្រង់បានបង្ខំយកស្ត្រីម្នាក់ដែលមានរូបឆោមលោមពណ៌ល្អ ប៉ុន្តែនាងមានប្ដីហើយ។ ប្ដីនាងនោះឈ្មោះកែវដោយមានការខឹងសម្បារនឹងពញាអនក៏បះបោរឡើង មានឈ្មោះថាកែវព្រះភ្លើង កដាកម្លាំងប្រឆាំងឡើងរួចធ្វើគុត ពញាអន បានសម្រេចនៅឆ្នាំ១៥៩៨។

បុត្រទី៣ របស់ព្រះសត្ថាទី១ នាមពញាញោមទ្រង់ទទួលងារជារាជានុសិទ្ធិនៅឆ្នាំ១៥៩៩ គឺមានសិទ្ធិដូចព្រះរាជាប៉ុន្តែមិនមែនជាព្រះរាជាពេញសិទ្ធិទេ។ ទ្រង់បានកម្ចាត់កែវព្រះភ្លើងបាន។ ដោយឡែករាជានុសិទ្ធិម្នាក់នេះមានចរិតមិនល្អ ចូលចិត្តតែខាងស្រីស្រា បរបាញ់សត្វ ចាប់ប្រពន្ធកូនអ្នកស្រុក អ្នកធ្វើខុសមិនជាប់ទោស ហេតុនេះហើយទាំងប្រជារាស្ត្រ ទាំងមន្ត្រី មានការមិនពេញចិត្តជាខ្លាំង។ ព្រះអយ្យការរបស់ទ្រង់ក៏សូមយាងព្រះបាទស្រីសុរិយោពណ៌ដែលគង់នៅស្រុកសៀម ព្រមទាំងរាជវង្សទាំងប៉ុន្មានមកស្រុកខ្មែរវិញ។ ជាដំបូងសៀមបានអនុញ្ញាតអោយតែព្រះបាទស្រីសុរិយោពណ៌ និងឧទ័យដែលជាបុត្រទីពីររបស់ស្រីសុរិយោពណ៌ មកជាមុន រីឯជ័យជេដ្ឋាទី២ ដែលជាបុត្រច្បងមិនទាន់បានមកនៅឡើយទេ។ ពញាញោមបានព្រមព្រៀងថ្វាយរាជសម្បត្តិទៅព្រះបាទស្រីសុរិយោពណ៌នៅឆ្នាំ១៦០០គ.ស ហើយទ្រង់នៅកាន់ឋានៈជាព្រះកែវហ្វាដដែល។

ព្រះបាទស្រីសុរិយោពណ៌យាងមកពីសៀមតាមច្រកកំពតនៅឆ្នាំ១៦០០ ហើយគង់នៅរាជវាំងកោះស្លាកែតដែលនៅក្នុងខេត្តកណ្ដាលសព្វថ្ងៃ។ ទ្រង់បានតែងតាំង តេជោយ៉តឱ្យធ្វើជាចៅហ្វាយខេត្តសំរោងទង ជំនួសតេជោមាសដែលបានស្លាប់ ហើយទ្រង់បានមកគង់នៅល្វាឯម។ ទ្រង់នៅស្រុកសៀមយូរបានទម្លាប់ព្រះកាយទ្រង់ទៅតាមបែបសៀម ដោយនិយមប្រើព្រះពស្ត្រលឿង និយាយភាសាសៀមច្បាស់ជាងភាសាខ្មែរ។ ទ្រង់បានឱ្យគេផ្លាស់សំលៀកបំពាក់សម័យលង្វែកចេញ ព្រមទាំងបានកែប្រែទំនៀមទម្លាប់នៃការប្រើពាក្យពេចន៍មួយចំនួនចេញដូចជា ទ្រង់បង្គាប់អោយគេហៅទ្រង់ថា ព្រះស្រីសុរិយោពណ៌មនាថ, ស្ត្រីដែលមានឋានៈខ្ពស់ត្រូវឆ្លើយនិងព្រះអង្គថា ព្រះពរ, ឆ្លើយនិងព្រះមហាក្សត្រីថា ព្រះម៉ែ, ឆ្លើយនិងពួកអ្នកអង្គម្ចាស់ថា ព្រះបាទម្ចាស់ ។ នៅឆ្នាំ១៦១៣ ទើបទ្រង់ទទួលបានការអភិសេក ជាស្ដេចពេញសិទ្ធិ។ ក្រោយមក ទ្រង់បានសុំពីសៀមមកវិញនូវបុត្រាច្បងរបស់ទ្រង់គឺ ជ័យជេដ្ឋាទី២ ដែលនៅឆ្នាំ ១៦១៨ ទ្រង់បានផ្ទេររាជសម្បត្តិអោយបុត្រច្បងនេះ។ ដោយធុញទ្រាន់ និងមេរៀនដដែលៗរបស់សៀមដែលតែងតែចិញ្ចឹមចិត្តវាយយកប្រទេសខ្មែរដាក់ជាចំណុះ ទ្រង់បានមើលឃើញកម្លាំងថ្មីមួយទៀតនៅភាគខាងកើតដែលទើបតែរំដោះខ្លួនចេញពីចំណុះប្រទេសចិន ហើយក៏ទើបតែលេបយកប្រទេសចម្ប៉ាបានថ្មីៗ នោះគឺប្រទេសអណ្ណាម ដោយទ្រង់បានផ្ញើសារទៅសុំចងមេត្រីភាពជាមួយ។ ចំណងមេត្រីភាពនេះបានចាប់ផ្តើម

ដោយការរៀបអភិសេក ព្រះបាទជ័យជេដ្ឋាទី២ និងបុត្រីក្សត្រអាណ្ណាម ព្រះនាងចូវ (ក្នុងភាសាអណ្ណាមហៅព្រះនាងថា ង៉ុកវ៉ាន់) នៅឆ្នាំ១៦១៨ ។ ពីរឆ្នាំក្រោយមក គឺនៅឆ្នាំ១៦២០ ទ្រង់បានយាងមកគង់នៅរាជធានីថ្មីឯឧដុង្គ ដែលស្តេចក្រោយៗមកទៀតសុទ្ធតែគង់ក្រុងឧដុង្គនេះដែរ ជាហេតុធ្វើឱ្យប្រវត្តិវិទូដែលសិក្សាពីប្រវត្តិសាស្ត្រខ្មែរបានកំណត់យកឆ្នាំ១៦២០ ជាឆ្នាំចាប់ផ្តើមនៃសម័យឧដុង្គ។

### ខ. សម័យឧដុង្គ៖

សម័យឧដុង្គបានចាប់ផ្តើមក្រោយពីព្រះបាទជ័យជេដ្ឋាទី២ ទ្រង់បានឡើងសោយរាជ្យពីព្រះបិតាគឺព្រះស្រីសុរិយោពណ៌ដែលទ្រង់បានផ្សំផ្គុំព្រះជ័យជេដ្ឋាទី២ នឹងបុត្រីស្តេចត្រាញ់យួនដើម្បីធ្វើជាសម្ព័ន្ធមិត្តទប់ទល់នឹងការលុកលុយរបស់សៀម។ សម័យកាលនោះមេទ័ពដែលល្បីឈ្មោះនៅក្នុងប្រវត្តិសាស្ត្រគឺតេជោមាស និងតេជោយ៉ត។ ឧដុង្គបើតាមរឿងនិទានយកឈ្មោះតាមតាចាស់ម្នាក់ឈ្មោះតាដុង្គ រឿងតំណាលថានៅពេលនោះមានក្សត្រមួយអង្គបានពេញចិត្តនឹងកូនស្រីរបស់គាត់។ ទើបក្រោយមក ព្រះរាជាក៏តាំងឈ្មោះនៅត្រង់នោះថា ឧដុង្គមានជ័យ លុះក្រោយមកទៀតក៏នៅហៅថា ឧដុង្គ ដូចសព្វថ្ងៃនេះ។

ព្រះបាទជ័យជេដ្ឋាទី២ បានឡើងសោយរាជ្យនៅរាជវាំងល្វាឯមក្នុងព្រះជន្ម៣៤វស្សា។ ព្រះអង្គមានមហេសីនាមអង្គចូវជាបុត្រីស្តេចយួន។ នៅឆ្នាំ១៦២០ ព្រះអង្គបានលើករាជធានីពីល្វាឯមមកឧដុង្គ។ ព្រះរាជកិច្ចដំបូងគឺកំណែទម្រង់ច្បាប់នៅក្នុងប្រព័ន្ធតុលាការខ្មែរ ដោយយល់ឃើញថាមានក្រមមួយចំនួនមិនទាន់មានភាពយុត្តិធម៌នៅឡើយ។ ព្រះអង្គបានកែប្រែក្រមបានចំនួន២៤។ ប៉ុន្តែការងារនេះត្រូវរំខានដោយសារការឈ្លានពានរបស់សៀមពីរលើកគឺនៅឆ្នាំ១៦២១ និង១៦២២។ ច្បាប់ដែលពិនិត្យរួចត្រូវដាក់ឱ្យអនុវត្តនៅឆ្នាំ១៦២៤នៅក្នុងតុលាការ។ ជាលើកទី១ ចាប់តាំងពីរជ្ជកាលព្រះបាទស្រីសុរិយោពណ៌រហូតដល់ជ័យជេដ្ឋាទី២ ពួកសៀមបានធ្វើការសាកល្បងដើម្បីដាក់ខ្មែរជាចំណុះម្តងទៀត។ នៅឆ្នាំ១៦២១ ស្តេចសៀមឈ្មោះសុងថាម បានលើកទ័ពដោយផ្ទាល់ជាពីរផ្នែក មួយផ្នែកចូលតាមខេត្តបាត់ដំបង និងពោធិ៍សាត់ ប៉ុន្តែត្រូវទ័ពខ្មែរវាយឱ្យខ្ចាត់ខ្ចាយរត់ចេញតាមខេត្តចន្ទបុរី។ មួយផ្នែកទៀតជាទ័ពជើងទឹកចូលមកតាមខេត្តកំពត និងបន្ទាយមាសក្នុងបំណងវាយយកខេត្តទ្រាំង ប៉ុន្តែទ័ពសៀមត្រូវបរាជ័យម្តងទៀត ដោយសារខ្មែរបំពុល។ មួយឆ្នាំក្រោយមកគឺឆ្នាំ ១៦២២ សៀមបានសាកល្បងលើកទ័ពមកម្តងទៀត ប៉ុន្តែត្រូវបរាជ័យ។ ចាប់តាំងពីពេលនោះមក រហូតដល់ដំណាច់សតវត្សទី១៧ សៀមពុំបានបញ្ចេញសកម្មភាពគាបសង្កត់ខ្មែរគួរឱ្យកត់សម្គាល់ឡើយ។ ប៉ុន្តែផ្ទុយទៅវិញ ពួកយួនបានចាប់ផ្តើមកេរទឹកដីខ្មែរ

បន្តិចម្តងៗពីខាងកើត។ ការរៀបអភិសេករវាងជ័យជេដ្ឋាទី២ និងក្សត្រីអង្គចូវបានធ្វើឱ្យប្រទេសខ្មែរជាប់ជំពាក់រឿងចម្រូងចម្រាស់យ៉ាងខ្លាំង នៅពេលដែលពួកយួនបានលេបយកទឹកដីចាម្ប៉ាទាំងស្រុងនៅសតវត្សទី១៧។ នៅឆ្នាំ១៦២៣ គណៈបេសកកម្មទូតយួន បានលើកសំណើសុំឱ្យយួនបង្កើតគ្រឹះស្ថានជំនួញនៅប៉ែកខាងត្បូងប្រទេសខ្មែរពីរមានខេត្តព្រៃនគរ និងកំពង់ក្របី ព្រមទាំងសុំអនុញ្ញាតឱ្យមានសិទ្ធិកាន់កាប់ក្រសួងគយនៅទីនោះផង។ ចំណុចនេះអ្នកប្រវត្តិសាស្ត្របានចាត់ទុកថា ខ្មែរចាញ់កលល្បិចបោកបញ្ឆោតរបស់យួនដែលសុំត្រួតពិនិត្យពន្ធដារនិងរស់នៅជាបណ្តោះអាសន្ន។ កាលដែលមិនទាន់សោយរាជ្យ ព្រះជ័យជេដ្ឋាទី២ មានព្រះជន្ម២៦វស្សា មានបុត្រពីរអង្គនាមថៅពញាតូ និងថៅពញានូ។ លុះសោយរាជ្យបាន២ឆ្នាំ ព្រះអង្គមានបុត្រនាមថៅពញាចន្ទ និងបុត្រីនាមចន្ទវតី (ឬបុប្ផាវតី)។ ឯព្រះឧទ័យរាជាមានបុត្រ៤អង្គ គឺអ្នកអង្គនន់ទី១ អ្នកអង្គសូរ អ្នកអង្គតន់ និងអ្នកអង្គអិម។

នៅសម័យឧដុង្គមានភាពចម្រូងចម្រាស់យ៉ាងខ្លាំងដោយសារតែមានទំនាស់វិបត្តិពោលគឺសង្គ្រាមរ៉ាំរ៉ៃ ការដណ្តើមរាជសម្បត្តិគ្នា ការឈ្លានពានពីសម្នាក់ប្រទេសជិតខាង និងទំនាស់ស្នេហាដ៏ល្បីល្បាញរវាងព្រះរាជសម្ភារ ឬព្រះថៅពញាតូ (ត្រូវជាក្មួយ) និងព្រះឧទ័យ (ដែលត្រូវជាឪពុកមា)។ នៅក្នុងសម័យឧដុង្គ ព្រះរាជាដែលមានទេពកោសល្យខ្លាំងក្នុងវិស័យអក្សរសាស្ត្រគឺមានមួយព្រះអង្គទៀតគឺព្រះអង្គដួងដែលព្រះអង្គបានបន្សល់ទុកស្នាដៃយ៉ាងចំណានសម្រាប់កូនខ្មែរជំនាន់ក្រោយ ។ ព្រះអង្គដួងនេះហើយជាព្រះមហាក្សត្រប្រកបដោយទសពិធរាជធម៌។ ពោលគឺនៅពេលដែលព្រះអង្គឡើងគ្រងរាជសម្បត្តិ គ្រានោះប្រទេសកម្ពុជាគ្រាំគ្រាជាខ្លាំងដោយស្ថិតក្រោមឥទ្ធិពលប្រទេសខ្លាំងទាំងពីរគឺសៀម និងយួនដែលមានគោលបំណងលេបត្របាក់យកទឹកដីនៃប្រទេសកម្ពុជា។ ដោយមើលឃើញពីទុក្ខវេទនារបស់ប្រជារាស្ត្រខ្មែរ ព្រះអង្គដួងទ្រង់សុខចិត្តទទួលយកឥទ្ធិពលនៃប្រទេសទាំងពីរ ដោយយល់ព្រមនាំសួយសារអាករទៅថ្វាយស្តេចនៃនគរទាំងពីរជារៀងរាល់ឆ្នាំ។ ក្រោយមកទៀត ព្រះអង្គបានប្រមើលមើលទៅកាន់អនាគតគឺថាត្រូវតែពឹងពរកប្រទេសមហាអំណាចបារាំងសែសមកជួយស្រុកខ្មែរ ទើបអាចរំដោះបានពីសត្រូវខ្លាំងទាំងពីរនេះបាន។ ព្រះអង្គដួង លោកបានបញ្ជូននិស្សិតខ្មែរឱ្យប្រឹងរៀនភាសាបារាំង ហើយបានសរសេរចុតហ្មាយទៅថ្វាយព្រះចៅណាប៉ូឡេអុង ប៉ុន្តែត្រូវបានសៀមចាប់បានជាច្រើនលើក។ ជាចុងបញ្ចប់ទ្រង់មានគោលបំណងដើម្បីវាយដណ្តើមយកទឹកដីកម្ពុជាក្រោមពីយួនមកវិញ ប៉ុន្តែជាអកុសលទ្រង់បានយាងសោយទិវង្គត ហើយបន្សល់ទុកនូវកិច្ចការជាច្រើនដែលអ្នកស្នងរបស់ព្រះអង្គគឺព្រះបាទនរោត្តម ឬព្រះអង្គម្ចាស់ប្រឡឹងជាអ្នកបន្តវេនដើម្បីធ្វើកិច្ចការដ៏សំខាន់មួយនេះ។

## II.៣.២- វិបត្តិភាពព្រះពុទ្ធសាសនាថេរវាទនៅសម័យកណ្តាល

ដោយសារតែសង្គ្រាមកើតមានមិនឈប់ឈរដែលបង្កឡើងដោយប្រទេសជិតខាងមានសៀម និង យួន ព្រមទាំងសង្គ្រាមក្នុងស្រុកនានាជាច្រើនបានបង្កឱ្យប្រទេសជាតិទាំងមូលត្រូវធ្លាក់ស្រុតបាត់កិត្យានុភាព អធិបតេយ្យភាព និងឱនភាពនៅគ្រប់វិស័យទាំងអស់ ក្នុងនោះព្រះពុទ្ធសាសនាបានហែលឆ្លងកាត់នូវព្រឹត្តិការណ៍សង្គមដ៏ស្មុគស្មាញ នេះដាមួយពុទ្ធបរិស័ទចំណុះជើងវត្តទូទាំងប្រទេសផងដែរ។ វត្តអារាមគម្ពីរដីកាត្រូវបានដុតបំផ្លាញ និងវាយកម្ទេច ឯព្រះសង្ឃត្រូវបានគេធ្វើគុត ឬត្រូវគេបណ្តេញចេញពីវត្តដោយគ្មានមូលហេតុច្បាស់លាស់ ក្រៅពីការបំផ្លាញដោយមិនរើសមុខ (ពីសម្នាក់ប្រទេសយួន)។ ទោះបីមានការព្យាបាទពីសំណាក់សត្រូវយ៉ាងណាក្តីក៏ព្រះពុទ្ធសាសនានៅតែតស៊ូ យ៉ាងរឹងមាំជាមួយនឹងពុទ្ធបរិស័ទគ្រប់ស្រទាប់វណ្ណៈផងដែរ។ ដោយសារតែសទ្ធាដែលកើតចេញពីជំនឿដ៏ជ្រះថ្លារបស់ប្រជាជនខ្មែរ ទាំងព្រះមហាក្សត្រ ទាំងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ បានខិតខំកសាង ជួសជុល និងធ្វើការរៀបចំវត្តអារាមពុទ្ធសាសនា ឱ្យមានដំណើរការឡើងវិញប្រកបទៅដោយស្មារតី សាមគ្គីដ៏ខ្ពង់ខ្ពស់។

ចុងសម័យអង្គរ ព្រះពុទ្ធសាសនាមហាយាន និងព្រហ្មញ្ញសាសនាចាប់ស្រុតចុះគួរឱ្យកត់សម្គាល់ ហើយពុទ្ធសាសនាថេរវាទក៏ចាប់មានឥទ្ធិពលយ៉ាងធំធេងនៅក្នុងស្ថានភាពដែលមានការប្រែប្រួលទាំងនេះ។ លោក ហារី បេនដា បានចាត់ទុកថា ព្រះពុទ្ធសាសនាថេរវាទនៅប្រទេសខ្មែរនៅចុងសម័យអង្គរ និងសម័យក្រោយអង្គរបន្តិចថាជាជំនឿនៃចលនាប្រជាជនទូទៅពោលគឺសាសនានេះមានបង្កប់នូវគំនិតប្រឆាំងនឹងរបបអភិជន។ ទស្សនៈរបស់លោក ហាក់ដូចជាឆ្លើយស្របទៅនឹងទស្សនៈរបស់លោក ឡឺក្លែរ ដែលជឿថា "ព្រះពុទ្ធសាសនាជាកត្តាដែលធ្វើឱ្យមានការលុបបំបាត់នូវប្រព័ន្ធវណ្ណៈ»។

ពង្សាវតារជាច្រើនបានបង្ហាញថារជ្ជកាលរបស់ព្រះបាទធម្មរាជា (១៤៨៦-១៥០៤) ថាជាយុគមាសនៃការរីកចម្រើនខាងជំនឿព្រះពុទ្ធសាសនា។ ស្តេចអង្គនេះបានឧបត្ថម្ភដល់ការកសាង និងពង្រឹងព្រះពុទ្ធសាសនាយ៉ាងខ្លាំងក្លា ដោយបានលើកលែងពន្ធអាករពីប្រជានុរាស្ត្រចំនួន៣ឆ្នាំថែមទៀតផង។ ព្រះអង្គក៏ជាមហាក្សត្រដែលមានចំណេះដឹងខាងពុទ្ធសាសនាមួយព្រះអង្គផងដែរ។ នៅរវាងឆ្នាំ១៤៩៦ ព្រះអង្គបានចេញរាជបញ្ជាឱ្យគេផ្ទេរព្រះសារីរិកធាតុទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធពីចេតិយរបស់ព្រះថោង នៅអង្គរមកតម្កល់នៅចេតិយថ្មីនៅភូមិខ្វាវព្រះធាតុ នៅជិតភ្នំសន្ទុក ខេត្តកំពង់ធំវិញ។

ក្រោយពេលព្រះបាទអង្គចន្ទសោយទិវង្គតទៅ ដោយគ្មានរាជបុត្រស្នងរាជ្យ ប្រទេសអណ្ណាមបានឆ្លៀតឱកាសលូកដៃចូលក្នុងកិច្ចការរាជវាំងខ្មែរ ដោយបានលើករាជបុត្រីមួយអង្គរបស់ព្រះអង្គចន្ទ ព្រះនាមអង្គម៉ីឱ្យឡើងសោយរាជ្យស្នងព្រះបិតា។ ឯប្រទេសអណ្ណាមក៏ឆ្លៀតឱកាសគ្រប់គ្រងប្រទេសកម្ពុជាតែម្តងទៅតាមរយៈការចាត់បញ្ជូនមេទ័ពមួយរូបឈ្មោះ ទ្រឿង មិញយ៉ាង ឱ្យមកគ្រប់គ្រងមើលការខុសត្រូវនៅកម្ពុជា។ គោលនយោបាយវៀតណាមភាវូបនីយកម្មត្រូវបានចាប់ផ្តើមធ្វើនៅទូទាំងប្រទេសកម្ពុជា ដោយដាក់បញ្ចូលនូវទំនៀមទម្លាប់ប្រពៃណីវៀតណាមជំនួសទំនៀមទម្លាប់ប្រពៃណីខ្មែរទាំងអស់។ វត្តអារាម គម្ពីរដីកា និងព្រះសង្ឃរងការបំពានដោយការបំផ្លាញ និងធ្វើគុតព្រះសង្ឃ។ ការងើបបះបោរកើតមានជាញឹកញាប់ប្រឆាំងនឹងវត្តមានអណ្ណាម និងការធ្វើទុក្ខបុកម្នេញលើព្រះពុទ្ធសាសនាក៏ដូចជាប្រជាជនខ្មែរទូទាំងប្រទេស។ គ្រានោះមានឧកញ៉ាម្នាក់បាននិយាយថា "យើងសប្បាយនឹងសម្លាប់ជនជាតិយួន យើងលែងខ្លាចពួកយួនទៀតហើយ គ្រប់សមរភូមិរបស់យើង ពួកយើងបានចងចាំជានិច្ចនូវព្រះត្រៃសរណគមន៍ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ" រហូតមកដល់រជ្ជកាលរបស់ព្រះអង្គឌួង ទើបគេសង្កេតឃើញថាសង្គមខ្មែរហាក់ដូចជាទទួលបានសន្តិភាព និងការអភិវឌ្ឍលើគ្រប់វិស័យឡើងវិញ ក្នុងនោះព្រះពុទ្ធសាសនាក៏ត្រូវបានស្តារ និងពង្រឹងពង្រីកឡើងវិញផងដែរ។ ទីអារាមដែលខូចខាតដោយសារការបំផ្លាញដោយសង្គ្រាម និងដោយហេតុផលផ្សេងៗត្រូវបានជួសជុល និងកសាងឡើងវិញក្រោមព្រះរាជូបត្ថម្ភរបស់ព្រះអង្គដួងផ្ទាល់ក៏ដូចជាក្រោមការជួយឧបត្ថម្ភរបស់មន្ត្រីរាជការទាំងឡាយដែលមានធនធានផងដែរ។ គេបានរៀបរាប់ថា នៅឆ្នាំ១៨៥៤ ព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី បានទ្រង់ឈ្វេងយល់ថា ក្នុងក្រុងកម្ពុជាធិបតី ព្រះពុទ្ធសាសនាបានទ្រុឌទ្រោមចុះ និងមិនច្បាស់លាស់ផង ត្បិតព្រះត្រៃបិដកពុំមានព្រះសូត្រក៏ពុំមានសម្រាប់ការរៀនសូត្រ ទើបព្រះអង្គបានប្រជុំសេនាបតីនាម៉ឺនសព្វមុខមន្ត្រីត្រាស់ថា គួរចាត់មន្ត្រី១រូប ឬអញ្ជើញព្រះរាជសារទៅស្រុកសៀមក្រាបបង្គំទូលស្តេចសៀម ព្រះចមក្លាវ (រាមាទី៤) ដើម្បីសូមទ្រង់តាំងព្រះត្រៃបិដក និងគណៈធម្មយុត្តក្នុងនគរខ្មែរ ដោយនិមន្តមហាប៉ានឱ្យទំនុកបម្រុងព្រះពុទ្ធសាសនាបានថ្កុំថ្កើងរុងរឿងតរៀងទៅ។

អវត្តមាននៃព្រះត្រៃបិដកនៅប្រទេសកម្ពុជាត្រង់ចំណុចនេះ ប្រហែលមិនមែនជាលទ្ធផលដែលកើតឡើងដោយសារតែសង្គ្រាមជាច្រើនសតវត្សរ៍យ៉ាងសាមញ្ញនោះទេ។ លោក ហ្វ្រង់ស្វា ប៊ីហ្សូត៍ បានអះអាងថាមុនការស្នើសុំរបស់ព្រះអង្គដួងនៅពាក់កណ្តាលសតវត្សទី១៩នោះ នៅក្នុងប្រទេសកម្ពុជាប្រហែលជាគេមិនធ្លាប់បានយកព្រះត្រៃបិដកមកប្រើឬក៏មិនស្គាល់ព្រះត្រៃបិដកទាំងស្រុងពីដើមដល់ចប់។

ទោះបីគេបានប្រើភាសាបាលីយ៉ាងទូលំទូលាយជាភាសាសាសនាតាំងពីសតវត្សទី១៣ ហើយយើងឃើញមានភស្តុតាងនៅក្នុងសិលាចារឹកដូចជាពាក្យ "ព្រះវិន័យ" "ព្រះអភិធម៌" និង "ព្រះសូត្រ" នៅប្រទេសកម្ពុជាក៏ដោយ លោក ប៊ីហ្សូត៍ ឱ្យយោបល់ថាចំណងជើងនៃ"ល្បីបី" (ព្រះត្រៃបិដក) ទំនងជាសំដៅលើក្បួនសម្រាប់ព្រះសង្ឃដែលក្នុងនោះមានសេចក្ដីសង្ខេបដែលបានដកស្រង់ចេញពីគម្ពីរបាលីបម្រុងសម្រាប់ឱ្យព្រះសង្ឃសូត្រ ប៉ុន្តែមិនចាំបាច់សិក្សា និងយល់ពីខ្លឹមសារទេ។ បញ្ញត្តិ និងសិក្ខាបទពុទ្ធសាសនា ដូចជាវិន័យសម្រាប់ប្រតិបត្តិនៅក្នុងវត្តជាប្រចាំថ្ងៃទូទៅ គេបានសរសេរជាអត្ថបទសម្រាយវិញ។ កាលលើកឡើងរបស់លោក ប៊ីហ្សូត៍ ទំនងជាវិភាគនូវស្ថានភាពមួយក្នុងសតវត្សទី១៩ ប៉ុណ្ណោះ។ ទស្សនៈដ៏សំខាន់មួយនៃកំណែទម្រង់ព្រះពុទ្ធសាសនាបានចាប់ផ្ដើមឡើងដោយព្រះបាទសម្ដេចព្រះហរិរក្សរាធិបតី ដើម្បីកត់សម្គាល់ការចាប់ផ្ដើមរជ្ជកាលរបស់ព្រះអង្គ គឺការប្រមូលឡើងវិញនូវគម្ពីរដែលបាត់បង់ ឬត្រូវបំផ្លិចបំផ្លាញនៅពេលមានសឹកសង្គ្រាមជាមួយនឹងសៀមនិងយួន។ ការស្តារគម្ពីរទាំងនោះឡើងវិញជានិមិត្តរូបនៃសកម្មភាពមួយក្នុងការធ្វើបុណ្យកុសលសម្រាប់ទ្រង់ និងអាណាចក្ររបស់ព្រះអង្គ ហើយក៏បានបង្ហាញផងដែរនូវទសពិធរាជធម៌របស់ព្រះអង្គដើម្បីលើកតម្កើង និងធ្វើឱ្យសាសនាបរិសុទ្ធ។ នេះគឺជាកាតព្វកិច្ចរបស់ព្រះអង្គដើម្បីការពារព្រះធម៌ តាមរយៈឥរិយាបថគំរូផ្ទាល់របស់ព្រះអង្គក្នុងការឧបត្ថម្ភព្រះសង្ឃ និងការយកចិត្តទុកដាក់ចំពោះគម្ពីរព្រះធម៌។

នៅក្នុងរជ្ជកាលព្រះបាទអង្គដួង ព្រះពុទ្ធសាសនាមានការអភិវឌ្ឍណាស់ ក្រោមព្រះរាជូបត្ថម្ភរបស់ព្រះអង្គផ្ទាល់ក៏ដូចជាការចូលរួមពីសម្នាក់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ព្រមទាំងប្រជាជនខ្មែរទូទៅដែលជាពុទ្ធបរិស័ទចំណុះជើងវត្តជិតឆ្ងាយផងដែរ។

## II.៣.៣- តួនាទីអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ

### II.៣.៣.១- អក្សរសិល្ប៍ពុទ្ធនិយម និងការបណ្ដុះបញ្ញាពុទ្ធិ

តាមការសិក្សាកន្លងមក យើងបានសង្កេតឃើញថា ស្នាដៃអក្សរសិល្ប៍ទាំងឡាយសុទ្ធសឹងតែមានតួនាទីក្នុងការផ្ដល់ពុទ្ធិ ចំណេះដឹងសព្វគ្រប់សារពើ។ យ៉ាងណាមិញ តាមរយៈស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរបានផ្ដល់នូវចំណេះដឹងផ្នែកព្រះពុទ្ធសាសនាយ៉ាងជ្រាលជ្រៅ។ ទស្សនវិជ្ជាព្រះពុទ្ធសាសនាបានសាបព្រោះមកក្នុងសង្គមខ្មែរ ផ្ទត់គំនិតមនុស្សខ្មែរដល់សរសៃសសូងតែម្តង។ ជាពិសេសក្នុងការប្រតិបត្តិតាមគន្លងមាគ៌ាព្រះពុទ្ធប្រកបដោយធម៌អហិង្សា ដោយសេចក្ដីសុខសន្តិភាព និងសុភមង្គល។

តាមរយៈស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមនាំឱ្យខ្មែរចេះស្រឡាញ់គ្នា មិនទ្រទ្រង់ភ្លើងចំណង់ដោយអំពើអាក្រក់ឡើយ។ នៅសម័យក្រោយអង្គរគឺជាសម័យកាលមួយដែលសង្គមខ្មែរជួបកលិយុគអាប់អួរក្រៃលែង ប៉ុន្តែអក្សរសាស្ត្រប្រែជាលេចធ្លោរហូតក្លាយជាយុគមាសនៃអក្សរសិល្ប៍ខ្មែរ។

យើងឃើញថា ស្នាដៃពុទ្ធនិយមបានបណ្តុះបញ្ញា ការចេះដឹងដល់ប្រជាជនខ្មែរឱ្យចេះដោះស្រាយបញ្ហាជីវិត មានស្មារតីតស៊ូ ហ៊ានជម្នះគ្រប់ឧបសគ្គ និងយកព្រះធម៌ជាទីពឹងទីរឭក។ ពោលគឺទាំងស្នាដៃនៅក្នុងទសជាតក បញ្ញាសជាតក និងសាស្ត្រាល្បែងនានាសុទ្ធតែជាកម្រងពុទ្ធិដ៏ឧត្តមរបស់កូនខ្មែរ ឱ្យចេះចាប់យកឱកាស ក្រេបយកចំណេះដឹងក្លាយជាមនុស្សល្អនៅក្នុងសង្គមជាតិ។ នៅសម័យកាលនោះតាមអ្វីដែលយើងបានសិក្សា អ្នកប្រាជ្ញ កវីនិពន្ធខ្មែរ សុទ្ធតែមានប្រភពធ្លាប់បានបួសរៀននៅក្នុងសម្នាក់ព្រះពុទ្ធសាសនា។ នៅក្នុងពេលបួសរៀននោះ គេបានសិក្សាធម៌អាថ៌ គម្ពីរព្រះត្រៃបិដក ភាសាបាលី-សំស្ក្រឹតដែលសុទ្ធសឹងតែជាជម្រៅនៃព្រះពុទ្ធសាសនា។

រាជកវីខ្មែរព្រះអង្គឌួង ទ្រង់គឺជាក្សត្រដែលយកព្រះទ័យទុកដាក់ចំពោះជាតិ និងអក្សរសាស្ត្រយ៉ាងខ្លាំង។ ទ្រង់ជារាជកវីដែលស្ថិតក្នុងសម័យឧដុង្គ ហើយព្រះអង្គតែងតែយកព្រះទ័យទុកដាក់ចំពោះជាតិប្រជារាស្ត្រជានិច្ច ។ នៅសម័យកាលនោះ អក្សរសាស្ត្រខ្មែរបានរីកចម្រើនដល់កម្រិតកំពូលរហូតដល់យើងចាត់ទុកថាជាយុគមាសនៃអក្សរសិល្ប៍ខ្មែរថែមទៀតផង ។ តាមការឱ្យដឹងពីព្រឹទ្ធាចារ្យ ឆេង ផុន យើងបានដឹងថានៅសម័យឧដុង្គ ព្រះរាជាទ្រង់ជាគណៈមេប្រយោគដោយផ្ទាល់ក្នុងការប្រឡងជ្រើសរើសមន្ត្រីរាជការឱ្យចូលធ្វើការនៅក្នុងវាំង ឬមុខការក្រសួងនានា។ ក្នុងនោះវិញ្ញាសាសំខាន់រួមមានប្រឡងកំណាព្យការប្រែលោតប្រយោគភាសាបាលីជាន់ខ្ពស់ជាដើម។ លោកបានដំណាលថានៅពេលជិតភ្លឺ ប្រជារាស្ត្រខ្លះដែលបានលីនង្គ័លទៅភ្ជួរស្រែបែរជាឈរទ្រើងរឹងខ្លួនពួនចាំស្តាប់សំឡេងសូរស័ព្ទស្នូត្រយ៉ាងពីរោះរណ្តំចិត្តដែលចេញមកពីរាជវាំងឧដុង្គមានជ័យក៏មានដែរ។ ត្រង់នេះយើងបានឃើញថា តម្លៃអក្សរសិល្ប៍បានជះឥទ្ធិពលមកលើសង្គមខ្មែរក្រៃលែង។ ហើយបើតាមសាស្ត្រាចារ្យភាសាបាលីគឺលោកតាផៃវិញ ហើយគាត់ជាសាក្សីរស់ដល់បច្ចុប្បន្ននេះ និងជាអ្នកគាត់តែងសៀវភៅប្រវត្តិសង្ខេបវត្តហរិរក្សរាជជិនី ហៅវត្តវាំងចាស់ លោកក៏បាននិយាយដែរថា នៅពេលដែលព្រះមហាក្សត្រខ្មែរបានប្តូររាជធានីពីឧដុង្គមករាជធានីភ្នំពេញ គ្រានោះនៅវត្តវាំងចាស់មានព្រះភិក្ខុសង្ឃមួយព្រះអង្គព្រះនាមមឿង មានបុណ្យបារមីអស្ចារ្យដែលគង់ប្រថាប់នៅវត្តវាំងចាស់នេះ។ សម័យកាលនោះជាសម័យកាលដែលសម្បូរទៅដោយអ្នកប្រាជ្ញ កវីនិពន្ធដែលមានស្នាដៃល្អឯកសម្រាប់កូនខ្មែរយ៉ាងច្រើនក្រាស់ក្រៃល។ បើនិយាយពីស្នាដៃវិញ ព្រះអង្គទ្រង់បាននិពន្ធរឿងកាកីដែលជាស្នាដៃតែងជាកំណាព្យប្រកបដោយកាព្យរូបារម្មណ៍ដ៏ល្អត្រកាល។ រឿងកាកីនេះ

យើងបានដឹងថាជាស្នាដៃដែលបានរំលេចឱ្យឃើញពីសោកនាដកម្មរបស់នាងកាកី ហើយចុងបញ្ចប់នៃជីវិតរបស់នាងគឺត្រូវស្លាប់យ៉ាងគួរឱ្យអាណោចអាធ័មក្រៃពេកដោយត្រូវបណ្ដែតពោងពាយលើក្បូនម្នាក់ឯងចូលទៅក្នុងមហាសាគរ។ នាងត្រូវបានតាឥសីរើសមកចិញ្ចឹមតាំងពីកំណើតមកម៉្លេះ។ នាងគ្មានម្ដាយឪពុកអប់រំទូន្មានប្រៀនប្រដៅដូចកូនគេដទៃឡើយ។ អាស្រ័យហេតុនេះហើយនៅពេលដែលស្ដេចព្រហ្មទត្តមកយកនាងជាមហេសីនោះ តាឥសីបានផ្ដាំផ្ញើថ្វាយព្រះរាជាថា ប្រសិនបើនាងមានកំហុសឆ្គង សូមទ្រង់កុំដាក់ទោសទណ្ឌនាងធ្វើអ្វី។ បានជាតាឥសីលោកបានផ្ដាំផ្ញើក្សត្រ ព្រោះលោកគិតថា នាងគ្មានម៉ែឪប្រៀនប្រដៅហ្នឹងគេឡើយ។ ដូចនេះ ថ្ងៃមុខនាងច្បាស់ជាប្រព្រឹត្តនូវកំហុសណាមួយជាក់ជាមិនខាន។ នៅក្នុងរឿងកាកីនេះដដែលក៏បានបង្ហាញពីចំណេះដឹងស្ដីពីជំនឿលើហោរាសាស្ត្រ ការទស្សន៍ទាយ ការសេកមន្តសារិកា ការប្រែកាឡាខ្លួន ការនិម្មិតខ្លួនជាអ្វីបានតាមចិត្តចង់របស់ខ្លួននោះជាដើម។ ជាក់ស្ដែងដូចជាគ្រុឌចេះកាឡាខ្លួនជាបុរសដែលមានរូបស្រស់សង្ហាដែលធ្វើឱ្យនាងកាកីចាប់អារម្មណ៍ដូចឃ្លាកំណាព្យលើកឡើងថា៖«ឯអង្គកាកី យល់គ្រុឌបក្សី មើលមកអាត្មា ញញឹមអរអៀន ចំហៀងនេត្រា ព្រឺព្រួចកាមា ត្រេកត្រង់ហឫទ័យ។ នាងធ្វើជាធ្លាក់ វំសាយសុភ័គ អំពីអង្សា គ្រុឌយល់សុជន ណែនក្ដន់ឱរា ព្រឺព្រួចចិន្ដា ស្រៀវស្រើបប្រតិព័ទ្ធ។ ស្ទើរស្ទុះទៅឱប ពារពក្រសោប ហោះចេញទៅថ្វាត់ មកគិតខ្លាចកេរ្តិ៍ ចំណេរមិនបាត់ ខះខំតែកាត់ ចិត្តថាំលេងស្ការ»។ គ្រុឌដោយមានចិត្តលើកាកី ក៏ឆក់យករូបនាងកាកីទៅស្ថានលំនៅរបស់ខ្លួន។ ចំណែកព្រះបាទព្រហ្មទត្តវិញ ទ្រង់បានចាត់ ហោរាគន់គូរមើល ទើបដឹងថានាងកាកីត្រូវគ្រុឌជាអ្នកចាប់យកទៅ។ រីឯគន្ធ័នវិញ ក៏ចេះប្រែកាឡាទៅតាមបំណងប្រាថ្នា ហើយតោងប្រាណគ្រុឌដល់ឋានសិម្ពលី និងបានជួបប្រាស្រ័យលួងលោមនាងកាកីបានដូច បំណង ហើយក៏ចុះមកវិញនាងស្ថានកណ្ដាល។ ត្រង់នេះជាចំណេះដឹងមួយដែលយើងគិតថា នៅសម័យកណ្ដាលប្រជាជនខ្មែរមានជំនឿទៅលើហោរាសាស្ត្រ និងជំនឿលើសិល្ប៍អាគមជាដើម។

ឆ្លងតាមការស្រាយបំភ្លឺ ស្នាដៃពុទ្ធនិយមញ៉ាំងឱ្យមនុស្សខ្មែរកាលពីសម័យក្រោយអង្គរមានបញ្ញាពុទ្ធិ ចេះដោះស្រាយបញ្ហា ជម្រុះចោលទស្សនៈភ័ន្តច្រឡំ ជម្រុះចោលភាពអសកម្ម ឱ្យស្រវាចាប់យកវិជ្ជាដាក់នៅក្នុងខ្លួនប្រសើរជាង។ ដូចនេះក្នុងនាមជាកូនខ្មែរត្រូវប្រឹងប្រែងក្រេបជញ្ជក់នូវការចេះដឹងគ្រប់សព្វសារពើ ហើយអាចនាំខ្លួនក្លាយជាឧត្តមជនជាក់ជាមិនខាន។

## II.៣.៣.២- អក្សរសិល្ប៍ពុទ្ធនិយម និងការអប់រំ

នៅក្នុងស្នាដៃពុទ្ធនិយម យើងបានសង្កេតឃើញថា អ្នកនិពន្ធខ្មែរបានយកការប្រៀនប្រដៅផ្សេងៗរបស់បុព្វបុរសខ្មែរផ្សារភ្ជាប់ជាមួយនឹងជីវិតព្រះពោធិសត្វមកតាក់តែងកែច្នៃបញ្ចេញបញ្ចូលគំនិតទស្សនៈ

របស់ខ្លួនឱ្យស្របទៅនឹងផ្នត់គំនិត ប្រពៃណីទំនៀមទម្លាប់របស់ប្រជាជនខ្មែរដើម្បីបណ្តុះស្មារតីឱ្យមនុស្ស យល់ដឹងពីតម្លៃនៃការប្រព្រឹត្តកុសលកម្ម បានសេចក្តីថាជាអំពើល្អ អំពើជាកុសល និងឱ្យលះបង់ចោល ចេញនូវអំពើបាបទាំងពួង។ ក្នុងនោះអក្សរសិល្ប៍ពុទ្ធនិយមបានបណ្តុះឱ្យខ្មែរមានការស្វែងយល់ស៊ីជម្រៅគឺ តម្លៃនៃការអប់រំតាមគន្លងមាគ៌ាព្រះពុទ្ធអង្គ និងការគោរពចំពោះព្រះពុទ្ធសាសនា។ ជាក់ស្តែងដូចជា៖

## ក. បណ្តុះស្មារតីមនុស្សឱ្យចេះដឹងគុណ និងជឿជាក់លើកម្លាំងខ្លួនឯង

ការផ្តើមរឿងដោយរំឭកគុណព្រះរតនត្រៃ រំឭកគុណគ្រូ គុណមាតាបិតា ប្រាប់ឈ្មោះអ្នកនិពន្ធ កាលបរិច្ឆេទ ខ្លឹមសាររឿង ដំណាលពីជីវិតរបស់ពោធិសត្វ និងការជួបជុំគ្រួសារ ព្រមទាំងបង្ហាញពីដំណើរ ជីវិតព្រះពោធិសត្វកាលទ្រង់យោនយកកំណើតនៅក្នុងជាតិផ្សេងៗ។

អក្សរសិល្ប៍ពុទ្ធនិយមប្រៀបបានជាឱសថដ៏ស័ក្តិសិទ្ធិគឺបានអប់រំមនុស្សខ្មែរឱ្យជឿទៅលើបុណ្យ បាប ខ្លាចអោអំពើបាប និងចៀសឱ្យឆ្ងាយពីបាបកម្មគ្រប់បែបយ៉ាង។ ស្នាដៃបានបណ្តុះចិត្តមនុស្សខ្មែរឱ្យ ចេះដឹងគុណចំពោះមនុស្សដែលបានជួយសង្គ្រោះខ្លួននៅពេលដែលខ្លួនជួបទុក្ខលំបាក។ នៅក្នុងសង្គម យើងនេះ យើងបានសង្កេតឃើញថា មនុស្សមានច្រើនប្រភេទណាស់ មានល្អ មានអាក្រក់ និងមានចិត្តជា គុណធម៌ជាដើម។ នៅក្នុងសង្គមទៀតសោត រមែងមានរឿងរ៉ាវជាច្រើនដលយើងមិននឹកស្មានដល់។ ដូច នេះគឺមានតែការខិតខំប្រព្រឹត្ត សាងតែអំពើល្អគ្រប់បែបយ៉ាង ទើបនាំឱ្យមនុស្សមានសុភមង្គល និងមាន ចិត្តស្ងប់នៅពេលដែលបានជួយសង្គ្រោះជនណាម្នាក់។ ខ្មែរយើងតែងមានជំនឿថា ការជួយសង្គ្រោះ មនុស្សសូម្បីតែម្នាក់នៅពេលដែលគេត្រូវការជំនួយ ល្អជាងការធ្វើបុណ្យ៧វត្ត។ ត្រង់នេះមនុស្សដែលគេ បានជួយសង្គ្រោះរមែងដឹងគុណ និងតបគុណនៅពេលដែលឱកាសហុចឱ្យ។ ជាមួយគ្នានេះ ស្នាដៃពុទ្ធ និយមបានបណ្តុះទស្សនៈឱ្យមនុស្សជឿជាក់លើកម្លាំងផ្ទាល់ខ្លួន មិនមានទស្សនៈផ្តេកផ្តួលដោយសេចក្តី ខ្ជិលច្រអូសសោះឡើយ។ តួយ៉ាងនៅក្នុងស្នាដៃរឿងមហោសថ យើងបានសង្កេតឃើញថា ព្រះមហោសថ មានព្រះប្រាជ្ញាក្រៃពេក។ ទ្រង់បានមើលដឹងពីល្បិចកលរបស់គូសត្រូវដែលមានបំណងមិនល្អ ឬធ្វើអំពើ បានធម៌ជាដើម។ ព្រះមហោសថរមែងប្រើប្រាស់នូវការវិភាគរបស់ខ្លួនប្រកបដោយបញ្ញាញាណដើម្បីដឹង ដើងការណ៍មុនជានិច្ច។

ត្រង់នេះយើងឃើញថា ស្នាដៃបានបណ្តុះនូវស្មារតីតស៊ូឱ្យមនុស្សជឿជាក់លើកម្លាំងផ្ទាល់ខ្លួន ជា ប្រយោជន៍ដ៏ក្រៃលែងសម្រាប់ជីវិតមនុស្សខ្មែរកាលពីសម័យបុរាណរហូតមកដល់បច្ចុប្បន្ន។

## ខ. អក្សរសិល្ប៍ពុទ្ធនិយមបណ្ដុះស្មារតីឱ្យមនុស្សជឿលើអំពើបុណ្យបាប

តាមរយៈស្នាដៃមួយចំនួនដូចជា ពុទ្ធិសែននាងកង្រី មរណមាតា សព្វសិទ្ធិ កវីនិពន្ធខ្មែរបានលើកឡើងពីការបញ្ហាកម្មផល។ តួអង្គដែលសាងអំពើអាក្រក់ រមែងមានកម្មពៀរវេរា ហើយត្រូវទទួលរងបាបកម្មចំពោះអំពើដែលខ្លួនបានសាងយ៉ាងសែនទារុណ។

នៅក្នុងរឿងពុទ្ធិសែននាងកង្រីបានបង្ហាញថា ពុទ្ធិសែន និងនាងកង្រីព្រាត់ប្រាសគ្នាដោយសារតែកម្មផល។ ចំណែកនាងទាំង១២ ត្រូវគេខ្វេះភ្នែក ខ្វាក់ភ្នែកដូច្នេះដោយសារតែកាលពីជាតិមុន នាងទាំងដប់ពីរនាំគ្នាខ្វេះភ្នែកត្រី ទើបជាតិបច្ចុប្បន្នត្រូវគេខ្វេះភ្នែកវិញ ហើយរស់នៅអន្ទោលអន្ទោកវេទនាពន់ពេកក្រៃ។ នាងពៅគេដែលខ្វេះភ្នែកត្រីតែម្ខាង ទើបជាតិបច្ចុប្បន្ននេះ នាងត្រូវគេខ្វេះភ្នែកតែម្ខាង ហើយអាចបម្រើបាយទឹកដល់បងៗ និងមើលថែទាំងកូនបាន។ ត្រង់ប្រការនេះក៏ជាការផ្សារភ្ជាប់របស់កវីនិពន្ធខ្មែរក្នុងគោលបំណងអប់រំប្រជាជនខ្មែរឱ្យជឿជាក់មកលើកម្មផល និងចង់បង្ហាញថាកម្មពៀរវេរាមានពិតប្រាកដមែន។ អ្នកណាសាងកម្មអ្វីគឺរមែងទទួលនូវកម្មនោះជាក់ស្ដែងស្របតាមអំពើដែលខ្លួនបានសាង។ ដូចនេះដើម្បីកុំឱ្យមានបាប គឺមនុស្សកុំត្រូវសាងអំពើបាបគ្រប់បែបយ៉ាង ឬវៀរចាកឱ្យឆ្ងាយពីអកុសលកម្ម។

នៅក្នុងរឿងមរណមាតា តួអង្គដែលប្រព្រឹត្តនូវអំពើបាបកម្មគឺនាងមេម៉ាយនាមកាឡី និងកូនៗទីបំផុតត្រូវកម្មពៀរវេរាមកផ្ដន្ទាយ៉ាងទាន់ហន់ជាទីបំផុត។ អំពើអាក្រក់នេះគឺជាអ្វីដែលកវីនិពន្ធអប់រំមនុស្សឱ្យខ្លាចកុំប្រព្រឹត្តនូវអំពើបាបកម្មឱ្យសោះ។ នៅក្នុងរឿងសព្វសិទ្ធិដែលនិពន្ធដោយហ្មឺនភក្ដីអក្សរ តន់ នាគ្រិស្តសករាជ១៨៩៩ បានបង្ហាញពីតួអង្គកីលៀងដែលមានចិត្តក្បត់នឹងម្ចាស់របស់ខ្លួន ទីបំផុតក៏ត្រូវកម្មតាមផ្ដន្ទាយ៉ាងអកុសលជាទីបំផុត។ នៅទីបញ្ចប់នៃរឿង កវីហ្មឺនភក្ដីអក្សរ តន់ បានលើកឡើងពីការសរជាតិដែលជាលក្ខណៈសម្គាល់នៃអក្សរសិល្ប៍ពុទ្ធនិយម។

ស្នាដៃពុទ្ធនិយមបានអប់រំ ដាស់តឿនក្រើនរំឭកមនុស្សខ្មែរឱ្យជឿលើកម្មផល វៀរចាកបាបកម្មគ្រប់បែបយ៉ាង។ ជាពិសេសគឺប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវសីល ចម្រើន ភាវនា ទើបនាំនាវាជីវិតរបស់ខ្លួនឱ្យបានសេចក្ដីសុខតរៀងអើយ។

## គ. អក្សរសិល្ប៍ពុទ្ធនិយមបណ្ដុះឱ្យមានស្មារតីតស៊ូគ្រប់កាលៈទេសៈ

ជាការពិតណាស់នៅក្នុងស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមមានតួនាទីយ៉ាងសំខាន់មួយទៀត គឺការអប់រំបានសេចក្ដីថាជាការទូន្មានប្រៀនប្រដៅដល់មនុស្សខ្មែរឱ្យមានចិត្តតស៊ូគ្រប់កាលៈទេសៈ និងយកទស្សនៈ

ទ្រឹស្ដីព្រះពុទ្ធសាសនាមកជាគ្រឿងអប់រំផ្លូវចិត្តរបស់ខ្លួន។ យើងអាចលើកឧទាហរណ៍ដាក់ស្ដែងគឺបណ្ឌិត ជ័យ នន្ទ ដែលជាកវីឆ្នើមនៅសម័យឧដុង្គ ពោលគឺនៅពេលដែលលោកជួបនូវទុក្ខក្រៀមក្រំពីព្រោះតែការបែកបាក់ព្រាត់ប្រាសពីប្រពន្ធកូន គ្រានោះហើយ លោកបានយកធម៌ព្រះពុទ្ធមកអប់រំ និងញ៉ាំងចិត្តឱ្យបានជ្រះថ្លាជានិច្ច។ ជាក់ស្ដែងដូចជាកំណាព្យខ្លះដែលលោកបានតាក់តែងមកនៅថៃ្ងនៃប្រាង្គប្រាសាទអង្គរវត្តជាតឹកតាងស្រាប់។ ឧទាហរណ៍ដូចជា៖

| | | | |
|---|---|---|---|
| «នេះភូជង្គលីលា | លើកដោយកាព្យ | ជាល្បាទាំងឡាយ | ។ |
| លាអស់លោកទោសសម្ងាយ | លាភ័យអន្តរាយ | ព្រាត់ព្រាយប្រាសគ្នា | ។ |
| ខ្ញុំក្រាបទូលព្រះពុទ្ធា | ព្រះហើយខ្ញុំលា | ត្រង់នាទុក្ខសោក | ។ |
| ខ្ញុំលាត្រង់កំណើតថោក | កើតមកអស់លោក | សើចដៀលសន្តាន | ។ |
| ខ្ញុំលាសព្វជាតិវៀរស្ថាន | ក្តីអាស្រូវប្រាណ | កុំមានឡើយណា | ។ |
| ខ្ញុំលាត្រង់ឥតប្រាជ្ញា | ឆ្ងល់ខ្លៅមោហា | ខ្មាសគេអៀនប្រៀន | ។ |
| ខ្ញុំលាត្រង់ឥតរបៀន | ចូលជំនុំស្ងៀម | ពុំចេះឆ្លើយថា | ។» (…) |

លោកបណ្ឌិត ជ័យ នន្ទ ជាកវីឆ្នើមនាសម័យកាលនោះដែលបានពលិកម្មដើម្បីជាតិ សាសនា និងព្រះមហាក្សត្រ។ យើងដែលជាកូនចៅជំនាន់ក្រោយពិតជាមានសេចក្ដីកោតស្ញប់ស្ញែងចំពោះទឹកដៃតែងនិពន្ធប្រកបទៅដោយរូបារម្មណ៍។ ស្នាដៃរបស់លោកគឺជាការត្រួសត្រាយផ្លូវសម្រាប់មនុស្សជំនាន់ក្រោយឱ្យមើលឃើញពីដំណើរជីវិត និងការយកទ្រឹស្ដីព្រះពុទ្ធសាសនាដែលប្រៀបបានជាឱសថមកព្យាបាលជំងឺផ្លូវចិត្តមនុស្សខ្មែរតាំងពីសម័យមុនរហូតមកដល់សម័យបច្ចុប្បន្ន ។

## II.៣.៣.៣- អក្សរសិល្ប៍ពុទ្ធនិយម និងការបណ្ដុះសោភ័ណជីវិត

ជាការពិតណាស់នៅសម័យកណ្ដាល អក្សរសិល្ប៍ពុទ្ធនិយមបានបណ្ដុះនូវមនោសញ្ចេតនា ពោលគឺសោភ័ណជីវិតពិតៗនាសម័យកាលនោះ។ ស្នាដៃពុទ្ធនិយមបានលើកកម្ពស់ស្មារតីម្ចាស់ការទទួលស្គាល់ការពិតដែលបុគ្គលគ្រប់រូបរមែងជួបប្រទះនៅលើវិថីជីវិតរបស់ខ្លួន។ ស្នាដៃពុទ្ធនិយមនាំឱ្យមនុស្សស្គាល់នូវភាពផ្អែមល្ហែម និងជូរចត់នៃជីវិត ព្រមទាំងកាលៈទេសៈដែលបានសេចក្ដីថាជាភាពចៃដន្យដែលកើតមានដោយមានអន្តរាគមន៍ពីទេវៈគ្រាពើបប្រទះនឹងការលំបាកជាដើម។

នៅត្រង់ស្នាដៃរឿងមួយចំនួនដូចជា ព្រះជិនវង្សដែលបានលាតត្រដាងពីការផ្សងព្រេងដ៏វែងអន្លាយរបស់តួអង្គថា ជីវិតពិតជាលំបាក ប៉ុន្តែមិនស្លាប់ឡើយ។ ព្រះជិនវង្សជាវីរជនដែលបានផ្សងព្រេងនៅគ្រប់ច្រកល្ហកនៃជីវិត ហើយនៅពេលទៅដល់ទីណាក៏ផ្សងព្រេងនឹងសេចក្តីស្នេហា ហើយដែលយើងឃើញថាតែងតែទទួលបានគូស្នេហ៍នៅទីនោះ។ ត្រង់ប្រការនេះហើយនាំឱ្យមនុស្សខ្មែរមានការចងចាំ និងជក់ចិត្តជិតអារម្មណ៍ទៅលើស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមពន់ពេកក្រៃ។ ប្រជាជនខ្មែរភាគច្រើនដែលនិយមចូលចិត្តរឿងនេះ ចងចាំទុក និងនិទានរឿងដំណាលប្រាប់ដល់កូនចៅជំនាន់ក្រោយមិនដែលភ្លេចឡើយ។ អាស្រ័យហេតុនេះទើបមានពាក្យបុរាណមួយដែលខ្មែរតែងនិយមពោលថា«ពូជព្រះជិនវង្សលំបាកបន្តិច ប៉ុន្តែមិនស្លាប់ឡើយ»។ ជាផ្នត់គំនិតរបស់ខ្មែរ គឺខ្មែរតែងប្រយុទ្ធតស៊ូដើម្បីបុព្វហេតុជាតិមាតុភូមិរបស់ខ្លួនគ្រប់កាលៈទេសៈដោយមិនអនុញ្ញាតឱ្យបរទេសជាន់ឈ្លីប្រមាថមាក់ងាយស្រេចតែអំពើចិត្តបានឡើយ។ ស្នាដៃពុទ្ធនិយមមានតួនាទីបណ្តុះឱ្យមនុស្សខ្មែរមានស្មារតីតស៊ូនៅក្នុងផ្លូវជីវិត ទោះបីជាពើបប្រទះទៅនឹងឧបសគ្គមករាំងដល់យ៉ាងណាក៏ដោយ។ បានសេចក្តីថា អក្សរសិល្ប៍ទាំងនោះបានកប់ជ្រៅទៅក្នុងសរសៃសសូងមនុស្សខ្មែរគ្រប់ស្រទាប់វណ្ណៈហើយតែងនិទានប្រាប់កូនចៅឱ្យបានដឹង និងមានស្មារតីក្រោកឈរទទួលបាននូវសោភ័ណជីវិតពិតៗ។ សោភ័ណជីវិតទាំងអស់នោះ បានដល់សោភ័ណចិត្ត សោភ័ណកាយ សោភ័ណទឹកដី សោភ័ណព្រៃព្រឹក្សា ពោលគឺសោភ័ណនៃធម្មជាតិដែលមានទាំងអស់នៅលើទឹកដីខ្មែរ។ ការបណ្តុះឱ្យស្រឡាញ់សោភ័ណជីវិតទាំងអស់នោះហើយ ញ៉ាំងឱ្យមនុស្សខ្មែរមានស្មារតីតស៊ូជម្នះរាល់ឧបសគ្គក្នុងការរស់នៅ ព្រមទាំងចេះសម្របខ្លួនទៅតាមបរិបទសង្គមជាក់ស្តែងថែមទៀតផង។ ជនជាតិខ្មែរជាជនជាតិមួយដែលមានអរិយធម៌ចំណាស់នៅតំបន់ឥណ្ឌូចិន ហើយដែលអាចនិយាយបានថាជាជាតិច្បង ឬជាទឹកដីសុវណ្ណភូមិដែលមានធនធានធម្មជាតិស្តុកស្តម្ភតាំងពីបុរាណកាលមក។ ត្រង់ប្រការនេះ មនុស្សខ្មែរត្រូវចូលរួមដើម្បីរក្សាឱ្យបានជាដាច់ខាតនូវបូរណភាពទឹកដីរបស់ខ្លួនឱ្យបានស្ថិតស្ថេរជាអង្វែងតរៀងទៅ។ អូមែដែលជាកវីនិពន្ធជនជាតិក្រិចបានពោលថា«សោភ័ណគឺជាធម្មជាតិ ធម្មជាតិគឺជាប្រភពនៃសោភ័ណគ្រប់បែបយ៉ាង»។ ជាការពិតណាស់ ធម្មជាតិគ្រប់បែបយ៉ាងនេះហើយបានផ្សារភ្ជាប់ទៅនឹងដួងចិត្តមនុស្សខ្មែរ ហើយមនុស្សខ្មែរមិនអាចកាត់ផ្តាច់ខ្លួនចេញពីមនោសញ្ចេតនាលើមាតុភូមិរបស់ខ្លួនបានឡើយ។ បានសេចក្តីថាអារម្មណ៍ដែលស្រឡាញ់ទឹកចិត្តដែលមានចំពោះជាតិមាតុភូមិរបស់ខ្លួនពិតជាជ្រាលជ្រៅជាទីបំផុត។ មនុស្សខ្មែរនៅតែរស់គ្រប់សម័យកាលដោយសារការតាំងចិត្ត និងសេចក្តីសង្ឃឹមរបស់ខ្លួនគ្រប់កាលៈទេសៈ។

ឆ្លងតាមការស្រាយបំភ្លឺខាងលើនេះ ស្នាដៃពុទ្ធនិយមបានបណ្តុះឱ្យមនុស្សខ្មែរមានស្នាមញញឹម មានសោភ័ណជីវិតពិតៗនៅក្នុងចិត្តគំនិតរបស់ខ្លួន។ យើងគប្បីថែរក្សាឱ្យបានជាដាច់ខាតនូវស្មារតីជាតិនិយមដើម្បីញ៉ាំងប្រទេសរបស់យើងឱ្យបានជឿនលឿនយ៉ាងជាក់ប្រាកដ។ ស្របពេលនាសម័យនេះ ខ្មែរចេះជួយចែករំលែកគ្នាដើម្បីរស់ប្រកបដោយសុខដុមនីយកម្ម។

## II.៣.៣.៤- អក្សរសិល្ប៍ពុទ្ធនិយម និងការចូលរួមអភិវឌ្ឍសង្គម

ស្នាដៃពុទ្ធនិយមជាច្រើនបានធ្វើឱ្យសង្គមនាសម័យកណ្តាលមានការងើបឡើងពីភក់ជ្រាំ ឬពីការគំរាមកំហែងពីបច្ចាមិត្រ។ ជាពិសេសស្នាដៃទាំងអស់នោះ បានជួយចម្រើនមិនត្រឹមតែផ្នែកស្មារតីនោះទេ ប៉ុន្តែថែមទាំងផ្តល់ឱ្យយើងនូវការចម្រើនផ្នែកសម្ភារៈថែមទៀតផង។

តាមរយៈប្រវត្តិសាស្ត្រខ្មែរយើងបានសង្កេតឃើញថា បន្ទាប់ពីការធ្លាក់ចុះខ្សោយនៅសម័យក្រោយអង្គរគឺនិន្នាការរបស់សង្គមបានងាកមករកព្រះពុទ្ធសាសនា។ និន្នាការនេះមិនមែនជារឿងដោយចៃដន្យឡើយ ប៉ុន្តែយើងអាចគិតថានេះក៏ព្រោះមនុស្សខ្មែរអាចមានការនឿយណាយនឹងជំនឿបែបព្រាហ្មណ៍និយមដែលដឹកនាំមនុស្សឱ្យជឿទៅលើទេវៈ។ ថ្វីបើខ្មែរងាកមកជឿទៅលើព្រះពុទ្ធសាសនា ប៉ុន្តែប្រជាជនខ្មែរមិនមានគំនិតផ្តេកផ្តួលនិយមទៅតាមតែកម្មផលឡើយ។ បានសេចក្តីថា ប្រជាជនប្រឹងប្រែងរស់ដោយខ្លួនឯង ប្រឹងធ្វើការចិញ្ចឹមជីវិត ធ្វើស្រែចម្ការច្បារដំណាំញ៉ាំងឱ្យជីវភាពរបស់ខ្លួនសម្បូរសប្បាយ។ ដោយឡែកទស្សនវិជ្ជាព្រះពុទ្ធសាសនាគ្រាន់តែជាបង្អែមក្លែមជីវិតផ្នែកស្មារតីរបស់ជនជាតិខ្មែរតែប៉ុណ្ណោះ។ ស្មារតីនៃការចូលរួមកសាងសង្គមជាតិមួយទៀតគឺតាមរយៈស្នាដៃរឿងព្រះមហាវេស្សន្តរជាតក ស្តែងតាមរយៈតួអង្គព្រះវេស្សន្តរតែម្តង។ ថ្វីបើស្នាដៃនេះជាស្នាដៃមួយដែលមាននៅក្នុងគម្ពីរព្រះត្រៃបិដកក៏ពិតមែន ប៉ុន្តែយើងជឿថា ស្នាដៃនេះពិតជាបានដក់ជាប់នៅក្នុងក្រអៅ បេះដូងមនុស្សខ្មែរដែលកាន់ព្រះពុទ្ធសាសនាគ្រប់កាលៈទេសៈ។ ព្រះវេស្សន្តរ ទ្រង់បានបំពេញទានបារមី។ តាមរយៈដំណើររឿង យើងបានឃើញថាព្រះវេស្សន្តរបានបរិច្ចាគទានតាំងពីចាកចេញពីផ្ទៃព្រះមាតា។ លុះដល់ទ្រង់ធំពេញវ័យ ទ្រង់បានបំពេញនូវសត្តសតកមហាទានដែលជាទានដ៏អស្ចារ្យដែលមាន៧០០មុខ ហើយក្នុងមួយមុខៗមាន៧០០របស់។ កុំថាឡើយត្រឹមទ្រព្យសម្បត្តិផ្ទាល់ព្រះអង្គ ឱ្យតែគេចង់បានទាំងព្រះកាយក៏ព្រះអង្គព្រមបរិច្ចាគជាទានដែរ។ ព្រះអង្គបានបរិច្ចាគដំរីបច្ច័យនាគេន្ទ្រដែលជាដំរីមង្គលដល់ព្រាហ្មណ៍ដែលមកពីនគរផ្សេង។ ថ្វីបើការបរិច្ចាគនោះធ្វើឱ្យប៉ះពាល់ដល់ទឹកចិត្តអ្នកស្រីពិរាស្ត្រក៏ដោយក៏ទ្រង់នៅតែបរិច្ចាគដែរ។ លើសពីនេះកុំថា

ឡើយទ្រព្យសម្បត្តិ ប្រពន្ធកូនក៏ព្រះអង្គបរិច្ចាគជាទានដែរ។ ស្មារតីពុទ្ធនិយមជាទ្រឹស្តីនាំទៅរកការអភិវឌ្ឍសង្គមជាតិចេះជួយសង្គ្រោះគ្នាទៅវិញទៅមក។ ការជួយជាអំណោយមិនមែនចេះតែឱ្យនោះឡើយ ប៉ុន្តែត្រូវផ្សារភ្ជាប់ទៅនឹងទ្រឹស្តីសង្គមផងដែរ។ ជាក់ស្តែងដូចជាសម័យបច្ចុប្បន្ន យើងមានកាកបាទក្រហម សមាគមនានាដែលចុះជួយប្រជាជននៅតាមមូលដ្ឋានក្នុងគ្រាលំបាកដូចជាគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងប្រធានសក្តិផ្សេងៗដែលកើតឡើងជាយថាហេតុ។ ឧទាហរណ៍ការជួយកសាងសាលារៀន មន្ទីរពេទ្យ វត្តអារាម សង់ស្ពាន សង់ផ្លូវថ្នល់ជាដើមដែលជាប្រយោជន៍សម្រាប់ជាតិ។ ការជួយសង្គ្រោះគ្នាជាកាយវិការដ៏ល្អរបស់ខ្មែរតាំងពីបុរាណមក។ ដោយឡែកនៅសម័យទំនើបនេះវិញ ពិភពលោកទាំងមូលកំពុងប្រឈមនឹងការរីករាលដាលនៃជំងឺកូវីត១៩ ដែលជាជំងឺសាកលនោះ មានប្រទេសជាមិត្តមួយចំនួនបានផ្តល់វ៉ាក់សាំង និងសម្ភារៈបរិក្ខារពេទ្យជាច្រើនជួយដល់កម្ពុជា។ នៅកម្ពុជាខ្លួនឯងក៏មានបណ្តាសប្បុរសជនគ្រប់ស្រទាប់បានស្រាក់ដៃគ្នាបរិច្ចាគប្រាក់ខែ ធនធាន សម្ភារៈជូនរាជរដ្ឋាភិបាលដើម្បីសង្គ្រោះប្រជាជនពីជំងឺឆ្លងកាចសាហាវ។ យើងសង្ឃឹមថា នេះជាការជួយគ្នាក្នុងគ្រាលំបាកដែលឆ្លុះបញ្ចាំងពីវប្បធម៌ចែករំលែកដ៏ល្អថ្លៃថ្លាក្នុងនាមជាមនុស្សជាតិ។

ឆ្លងតាមការស្រាយបំភ្លឺខាងលើនេះ ស្មារតីពុទ្ធនិយមពិតជាបានចូលរួមលើកកម្ពស់សង្គមខ្មែរនាសម័យកណ្តាលឱ្យមានការចែករំលែកគ្នា ជួយគ្នាក្នុងគ្រាលំបាក និងកសាងសង្គមខ្មែរឱ្យមានការរីកលូតលាស់គ្រប់សម័យកាល។ ស្របតាមពំនោលខ្មែរតែងពោលថា«ជួយគ្នាក្នុងគ្រាក្រ មិត្តល្អស្គាល់គ្នាក្នុងគ្រាលំបាក»ជាដើម។

## II.៣.៣.៥- អក្សរសិល្ប៍ពុទ្ធនិយម និងបញ្ហានយោបាយ

អក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរក៏ដើរតួនៅក្នុងនយោបាយផងដែរគឺតាមរយៈទ្រឹស្តីព្រះពុទ្ធសាសនាដូចជា «អត្តាហិ អត្តនោ នាថោ ឬខ្លួនទីពឹងខ្លួន»។ ទ្រឹស្តីនេះជាមាគ៌ាដឹកនាំជីវិតឱ្យបានផ្ទុះផង់ និងជឿនលឿន។ សង្គមខ្មែរតាំងពីបុរាណកាលមក មនុស្សខ្មែរមានស្មារតីម្ចាស់ការ មានចរិតឯករាជ្យ និងពឹងលើដៃខ្លួនឯងទាំងគូ។ មនុស្សខ្មែរនិយមពឹងលើសមត្ថភាពផ្ទាល់ខ្លួនជាជាងមានទស្សនៈពឹងលើអ្នកដទៃ ឬពឹងលើកម្លាំងទេវៈ។

ត្រង់នេះយើងអាចសង្កេតបានតាមព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៅសម័យឧដុង្គ។ គ្រានោះប្រទេសខ្មែរស្ថិតក្រោមការត្រួតត្រារបស់អណ្ណាម ហើយស្តេចអណ្ណាមបានលើកបន្ទុបក្សត្រី អង្គម៉ីឱ្យឡើងគ្រងរាជ

សម្បត្តិ រួចបានបង្ខំខ្មែរឱ្យគោរពប្រពៃណីបែបយួន កាប់ដើមពោធិ៍បំផ្លាញព្រះពុទ្ធសាសនា។ ក្រោមមេបញ្ជាការយួនគឺទ្រឿង មិញយ៉ាង បានដាក់បញ្ជាយ៉ាងតឹងរ៉ឹង និងដាច់ណាត់គ្មានធម៌ប្រណីមកលើប្រជាជនខ្មែរ។ ប៉ុន្តែគ្រានោះ ប្រជាជនខ្មែរមានកំហឹងទៅលើស្តេចយួនយ៉ាងខ្លាំង ហើយក៏តាំងងើបឡើងបះបោរបង្កចលាចលកាប់សម្លាប់យួនទូទាំងប្រទេសដោយឥតរើសមុខ។ គ្រានោះយួនមិនអាចគ្រប់គ្រងខ្មែរបានឡើយ ព្រោះខ្មែរបានយកត្រៃសរណគមន៍មកជាទីពឹងជាទីរំឭក ហើយបើនរណាមកប៉ះពាល់ដល់ព្រលឹងដួងជាតិរបស់ខ្លួនហើយ ខ្មែរច្បាស់ជាក្រោកឡើងប្រឆាំងតបតវិញជាក់ជាមិនខាន។ ស្នាដៃពុទ្ធនិយមនៅក្នុងសេចក្តីផ្តើមតែងរំឭកគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងគុណមាតាបិតាជាដើមដែលនេះជាធម៌កតញ្ញូនិងការដឹងគុណចំពោះត្រៃសរណគមន៍។ ត្រង់ប្រការនេះហើយ យើងអាចនិយាយបានថា ពុទ្ធនិយមនៅសម័យកណ្តាលមិនត្រឹមតែជាអក្សរសិល្ប៍-សិល្បៈប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាឥទ្ធិពលនៃនយោបាយក្នុងសង្គមខ្មែរថែមទៀតផង។

ដូចនេះអក្សរសិល្ប៍ពុទ្ធនិយមជាអាវុធដ៏អស្ចារ្យដែលអាចកែប្រែដោគវាសនារបស់មនុស្ស ហើយឱ្យមានជំនឿជឿជាក់យ៉ាងមុតមាំលើព្រះពុទ្ធសាសនាដែលជាស្មារតីវិទ្យាសាស្ត្រ និងទស្សនវិជ្ជា។

## II.៣.៣.៦- អក្សរសិល្ប៍ពុទ្ធនិយម និងការព្យាបាលផ្លូវចិត្ត

អក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរប្រៀបបានដូចជាឱសថដ៏ស័ក្តិសិទ្ធិដែលបានជួយព្យាបាលជំងឺផ្លូវចិត្តប្រជាជនខ្មែរឱ្យមានសេចក្តីសុខស្ងប់ស្ងាត់។ តាមប្រវត្តិសាស្ត្រ យើងបានឃើញថាប្រទេសកម្ពុជានាសម័យនោះមានចម្បាំងរាំងដល់មិនចេះល្ហែល្ហើយ។ ចម្បាំងទាំងអស់នោះកើតឡើងដោយកត្តាផ្ទៃក្នុងផង និងកត្តាបរទេសឈ្លានពានខាងក្រៅផងដែរ។ អាស្រ័យហេតុនេះ អក្សរសិល្ប៍ពុទ្ធនិយមជាស្នាដៃដ៏មានតម្លៃជាទីបំផុតដែលអាចជួយជម្រុះចោលនូវរឿងសៅហ្មងទាំងឡាយបាន។

ប្រការមួយទៀតជាការកត់សម្គាល់ស្នាដៃទាំងនោះជាសិល្បៈសម្រាប់កម្សាន្តនៅពេលទំនេរពីការងារពលកម្មធ្វើស្រែចម្ការជាដើម។ នៅពេលដែលប្រជាជនខ្មែរសម្រាកពីការងារស្រែចម្ការ គឺពួកគាត់តែងតែនិទានរឿងដែលបានចងចាំ ឬការនិយមសូត្រកំណាព្យឱ្យស្តាប់ក៏ជាវិធីមួយល្អផងដែរ។ ត្រង់នេះហើយ ទើបយើងអាចនិយាយបានថា ស្នាដៃពុទ្ធនិយមជាឱសថព្យាបាលជំងឺផ្លូវចិត្តរបស់ប្រជាជនឱ្យល្ហែល្ហើយពីការលំបាក។ នៅសម័យក្រោយអង្គរ យើងបានដឹងថា ប្រទេសជាតិកំពុងញាំញីដោយវិបត្តិជាច្រើនដែលកើតឡើងដោយសារជម្លោះផ្ទៃក្នុង និងបច្ចាមិត្តពីខាងក្រៅ។ ក្នុងនោះសត្រូវខ្លាំងគឺសៀម ហើយនឹង

យួនតែងតែចិញ្ចឹមចិត្តមកលើនគរខ្មែរ ហើយធ្វើសង្គ្រាមនៅលើទឹកដីខ្មែរដោយបែងចែកម្ខាងម្នាក់នៃទន្លេមេគង្គជាខ្សែបន្ទាត់កាន់កាប់រៀងខ្លួន។ តាមឯកសារមហាបុរសខ្មែរ ដែលរៀបរៀងដោយលោក អេង សុត បាននិយាយថា ប្រជារាស្ត្រខ្មែរនៅត្រើយខាងកើតធ្វើស្រែស្រូវបានចិញ្ចឹមទ័ពយួន រីឯប្រជារាស្ត្រខ្មែរនៅត្រើយខាងលិចធ្វើស្រែស្រូវបានចិញ្ចឹមទ័ពសៀម។ ត្រង់នេះហើយដែលធ្វើឱ្យប្រជារាស្ត្រខ្មែរវេទនាឥតមានពេលស្រាកស្រាន្ត។ ម្ល៉ោះហើយ អក្សរសិល្ប៍ពុទ្ធនិយមបានជួយបន្ធូរបន្ថយភាពតានតឹងផ្នែកផ្លូវចិត្តរបស់គេដោយប្រជារាស្ត្រខ្មែរងាកមកមានជំនឿទៅលើព្រះរតនត្រ័យ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ថាអាចជួយស្រោចស្រង់ពួកគេឱ្យមានសេចក្ដីសង្ឃឹម។ នេះជាព្រលឹងដួងកែវធំណាស់សម្រាប់ជាតិ គឺព្រលឹងសាសនាដែលបានជួយជំរុញទឹកចិត្តប្រជារាស្ត្រខ្មែរឱ្យមានសេចក្តីសង្ឃឹមនៅក្នុងជីវិត។ ដូចដែលយើងបានដឹងស្រាប់មកហើយថា កាលពីសម័យដើមវត្តអារាមជាទីកន្លែងបណ្ដុះបណ្ដាលការសិក្សារៀនសូត្រសព្វគ្រប់សារពើ។ កូនប្រុសច្រើនតែមានឱកាសក្នុងការមកបួសរៀនសូត្រនូវវិជ្ជាផ្នែកខាងព្រះពុទ្ធសាសនា និងកិច្ចការងារ ហត្ថកម្ម សិល្បៈជាដើមដែលនេះជាប្រពៃណីរបស់ខ្មែរយើងតាំងពីដើមរៀងមក។ ស្នាដៃរឿងទាំងឡាយប្រៀបបានជាឱសថលាងជម្រះភាពនឿយហត់ឱ្យសប្បាយរីករាយ និងមានក្ដីសង្ឃឹមក្រោយពីបានអាន សូត្រកំណាព្យចេញពីសាស្ត្រាល្បែងនានាដូចជារឿងព្រះជិនវង្ស ស្រទបចេក ហង្ស យន្ត ទេវន្ទ សព្វសិទ្ធិ មរណមាតាជាដើម។ រឿងទាំងអស់នេះ ប្រជាជនខ្មែរនិយមចងចាំ និងនិទានតៗគ្នាទុកឱ្យកូនចៅជំនាន់ក្រោយស្ដាប់លេងកម្សាន្តនៅពេលសម្រាកពីការងារ។ ជួនកាលគេយករឿងទាំងនោះមកច្រៀងលេងចាប៉ីថែមទៀតផង។ ចំពោះរឿងទុំទាវក៏ជាស្នាដៃដែលបានកើតឡើងនៅសម័យលង្វែកផងដែរ។ រឿងនេះចារឹកទុកនៅក្នុងឯកសារមហាបុរសខ្មែរដែលថាកើតមានពិតនៅសម័យលង្វែក។ រឿងនេះត្រូវបានគេយកមកច្រៀងចាប៉ី សាដៀវ ហើយមានអ្នកនិពន្ធជាច្រើនរូបដូចជាសន្ធរម៉ុកជាដើម។ លុះក្រោយមកព្រះភិក្ខុសោមបានរៀបរៀងនិពន្ធសាជាថ្មី ជាបទពាក្យ៧តាំងពីដើមរហូតដល់ចប់។ រឿងនេះទៀតសោតមានតម្លៃគ្រប់សម័យកាល ព្រោះបានបង្ហាញពីតម្លៃសាកលភាពនៃស្នាដៃ។

ឆ្លងតាមការស្រាយបំភ្លឺខាងលើនេះ យើងបានឃើញថា ស្នាដៃពុទ្ធនិយមបានជួយព្យាបាលជំងឺផ្លូវចិត្តរបស់ប្រជាជនខ្មែរនៅសម័យក្រោយអង្គរឱ្យបានស្រាកស្រាន្ត បន្ធូរបន្ថយភាពតានតឹងក្នុងផ្លូវអារម្មណ៍ និងមានស្មារតីតស៊ូនៅក្នុងជីវិត។ ជាពិសេសស្នាដៃបានរំលេចឱ្យឃើញពីការបម្រើផ្នែកស្មារតី បំពេដួងចិត្ត និងផ្លូវចិត្តប្រជាជនឱ្យបានសេចក្ដីសុខក្សេមក្សាន្តជារៀងរាប។ ក្នុងនាមជាកូនខ្មែរពិតជាមានមោទនភាពដែលបានកើតមកបម្រើជាតិ សាសនា និងព្រះមហាក្សត្រដែលជាបាវចនាជាតិលុះគ្រាអវសាន។

## II.៣.៣.៧- អក្សរសិល្ប៍ពុទ្ធនិយម និងសង្គមវប្បធម៌

អក្សរសិល្ប៍ពុទ្ធនិយមជាស្នាដៃដែលបង្កប់តម្លៃសង្គមវប្បធម៌នៅក្នុងនោះផងដែរ។ សង្គមធម៌ដែលមាននៅក្នុងស្នាដៃត្រូវបានប្រជាជនខ្មែរនិយមយកមកបង្ហាញតាមរយៈទំនៀមទម្លាប់ប្រពៃណីរបស់ខ្លួន។ ជាក់ស្តែង យើងឃើញថានៅលើទឹកដីខ្មែរមានបូជនីយដ្ឋានជាច្រើនពាសពេញប្រទេស ហើយជាកន្លែងដែលរក្សាទុកនូវមរតកវប្បធម៌ជាតិខ្មែរតាំងពីបុរាណកាលរហូតដល់សម័យបច្ចុប្បន្ន។

អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមមានឥទ្ធិពលលើវិស័យហោរាសាស្ត្រ វិស័យនយោបាយ វិស័យច្បាប់ វិស័យសិល្បៈជាដើម។ ក្នុងវិស័យសិល្បៈត្រូវបានគេយកស្នាដៃរឿងទាំងនោះ ថតជាខ្សែភាពយន្តលេងជាល្ខោនបាសាក់ ល្ខោននិយាយ ល្ខោនស្បែកពណ៌ ល្ខោនស្បែកតូច ចម្រៀង ជាចម្លាក់ ជាសិល្បៈសូនរូប ជាគំនូរជាដើម។ នៅតាមវត្តនីមួយៗឃើញមានរូប ចម្លាក់ព្រះវេស្សន្តរបរាជរថ តាជូជកឡើងដើមឈើមានផ្លែពីរដេញខាំ តាជូជកដឹកដៃនាងអមិត្តជីតាបនា ព្រះសុវណ្ណសាម ព្រះមហោសថនៅតាមទីធ្លាក្នុងវត្តដើម្បីបង្ហាញប្រាប់មនុស្សទូទៅបានយល់ដឹងពីសកម្មភាព និងរូបរាងរបស់តួអង្គនីមួយៗ។ មិនតែប៉ុណ្ណោះនៅតាមវត្តនានាក្នុងព្រះរាជាណាចក្រកម្ពុជាស្ទើរគ្រប់វត្តទាំងអស់សុទ្ធតែមានគំនូររឿងទសជាតកនៅតាមជញ្ជាំងព្រះវិហារ ឬជញ្ជាំងសាលាឆាន់ដើម្បីបង្ហាញពីដំណើរជីវិតផ្សេងៗដែលតួអង្គនីមួយៗបានប្រព្រឹត្តដល់ពុទ្ធបរិស័ទបានយល់។

តាមរយៈស្នាដៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម យើងឃើញមានបទពិសោធសម្បូរបែបនៃការផ្តល់យុត្តិធម៌ក្នុងសង្គម។ ការផ្តល់យុត្តិធម៌ពីសម័យបុរាណគឺផ្អែកលើព្រឹត្តិការណ៍ ឬស្ថានការណ៍ ការធ្លាប់អនុវត្តតថភាពពិត ហេតុការណ៍ពិតជាក់ស្តែង និងការឱ្យតម្លៃលើហេតុផលដើម្បីវិនិច្ឆ័យទោស។ មនុស្សរស់នៅក្នុងសង្គមតែងត្រូវការយុត្តិធម៌ និងការទទួលបានយុត្តិធម៌ វាជាបញ្ហាដ៏ស្មុគស្មាញបំផុតសម្រាប់បុគ្គល និងសង្គមនីមួយៗ។ លក្ខណៈនៃការផ្តល់យុត្តិធម៌ និងទទួលបានយុត្តិធម៌មានបែបផែនឬវិធីផ្សេងៗពីគ្នាទៅតាមសម័យកាលនីមួយៗ ឧទាហរណ៍នៅក្នុងស្នាដៃពុទ្ធនិយមជាច្រើន ពិសេសនៅក្នុងរឿងមហោសថយើងឃើញការផ្តល់យុត្តិធម៌មានតាមរបៀបផ្សេងៗគ្នាទៅតាមបញ្ហាដែលកើតមានឡើង។ មិនត្រឹមតែរបៀបផ្តល់យុត្តិធម៌ប៉ុណ្ណោះទេ អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមនេះបានបង្ហាញពីទសពិធធម៌ដែលមានចែងនៅក្នុងកុដិសាសនារបស់ខ្មែរយើង ហើយត្រូវខ្មែរយើងចាត់ទុកដូចជាវិន័យ ឬច្បាប់សម្រាប់ទូន្មាន និងបង្ហាញពីគុណសម្បត្តិ ព្រមទាំងបុគ្គលិកលក្ខណៈល្អនៃបុគ្គលដែលអ្នកគ្រប់គ្រងក្នុងសង្គម។ ទសពិធរាជ

ធម៌ដែលបានបង្ហាញក្នុងរឿងវេស្សន្តរនោះគឺមាន៖ ១ ទាន ការធ្វើអំណោយ, ២-សីល ការរក្សាសីល៥ជានិច្ច ឬរក្សាសីល១០ មួយដងមួយកាល ៣-បរិច្ចាគ ការចំណាយព្រះរាជទ្រព្យទំនុកបម្រុងប្រទេសជាតិ, ៤-អាជ្ជវៈ មានសេចក្តីត្រង់, ៥-មទ្ទវៈ មានសេចក្តីទន់ភ្លន់ស្លូតសុភាពរាបសា, ៦-តបៈ ការកាន់ឧបោសថសីល តាមកាលកំណត់ម្តងៗ, ៧-អក្កោធនៈ មិនកម្ដៅក្រហាយអ្នកដទៃ, ៨-អវិហឹសា មិនបៀតបៀនអ្នកដទៃ ៩-ខន្តិ មានសេចក្តីអត់ធន់, ១០-អវិរោធនៈ មិនបំពានលើធម៌លើច្បាប់។ តាមរយៈខ្លឹមសារនិងបទពិសោធដែលបានបង្ហាញក្នុងរឿងវេស្សន្តរនេះ យើងយល់ថាបើអ្នកមានអំណាចគ្រប់គ្រងរដ្ឋ ទោះអំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិក្តី និងតុលាការក្តីបានតម្កល់ខ្លួននៅក្នុងទសពិធរាជធម៌ទាំង១០នេះ លោកអាចត្រូវចាត់ទុកថាជាបុគ្គលជាថ្នាក់ដឹកនាំដ៏ល្អដែលប្រកបដោយធម៌។

ឆ្លងតាមការស្រាយបំភ្លឺខាងលើនេះ ស្នាដៃពុទ្ធនិយមពិតជាបានផ្សារភ្ជាប់ទៅនឹងសង្គមធម៌នៅក្នុងសង្គមខ្មែរជាក់ប្រាកដមែន។ ដូចនេះក្នុងនាមជាកូនខ្មែរគ្រប់ប្រាណគប្បីព្យាយាមសិក្សាស្វែងយល់ និងរក្សាឱ្យបាននូវព្រលឹងអក្សរសិល្ប៍ពុទ្ធនិយមឱ្យបានជានិរន្តរ៍តរៀងទៅ។

## II.៣.៣.៨- អក្សរសិល្ប៍ពុទ្ធនិយម និងព្រលឹងជាតិខ្មែរ

ស្នាដៃពុទ្ធនិយមបានឆ្លុះបញ្ចាំងពីព្រលឹងជាតិខ្មែរ។ តើព្រលឹងជាតិខ្មែរនោះមានអ្វីខ្លះ? ហើយព្រលឹងជាតិបានដើរតួនាទីយ៉ាងដូចម្តេចខ្លះនៅក្នុងជីវិតមនុស្សខ្មែរ? យើងបានដឹងហើយថា ជនជាតិខ្មែរជាជាតិសាសន៍ដ៏ចំណាស់មួយនៅតំបន់អាស៊ីអាគ្នេយ៍យើងនេះ។ ជនជាតិនេះមានវប្បធម៌ដើមរបស់ខ្លួនមុនពេលដែលឥណ្ឌាចូលមកទៅទៀត។ តាមឯកសារស្តីពីប្រវត្តិរបស់ជនជាតិខ្មែរដោយអ្នកប្រាជ្ញបារាំងល្វី ហ្វីណូ ដែលបានសរសេរនៅក្នុងស្នាដៃប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា «តាមប្រវត្តិវិទូចិនជនជាតិខ្មែរជាជនជាតិមួយដែលជាមិត្តជិតខាងល្អរបស់ប្រទេសចិន និងដែលមានបឋមក្សត្រីខ្មែរដំបូងព្រះនាមថាលីវយី ហើយក្រោយមកក្សត្រីអង្គនេះរៀបអភិសេកជាមួយនឹងរាជបុត្រឥណ្ឌា។

តាមឯកសាររបស់លោក សរ សារុន ក្នុងសៀវភៅមានចំណងជើងថា «សាកល្បងសិក្សាអំពីសង្គមវិជ្ជាខ្មែរ»បោះពុម្ពឆ្នាំ១៩៧៣ ព្រលឹងខ្មែរមាន១០រួមមាន៖ ១-ខ្មែរគោរពរបបមាតាធិបតេយ្យ ២-កម្លាំងការពាររបស់ខ្មែរ ៣-ខ្មែរចូលចិត្តអួត ៤-ខ្មែរជាប្រទេសកសិកម្ម ៥-ខ្មែរពុំសូវចេះគោរពច្បាប់ ៦-ខ្មែរជាជនជាតិអកម្ម ៧-ខ្មែរជាជនជាតិប្រចាំប្រកូវ ៨-ខ្មែរទំនោរទៅរកទស្សនៈជ្រុលនិយម ៩-ខ្មែរចូលចិត្តនិយាយពាក្យសច្ចៈ និងព្រលឹងទី១០ ខ្មែរមានភក្តីភាពនៃព្រហ្មចារី។ ប៉ុន្តែអ្វីដែលយើងចង់លើកយកបង្ហាញនៅក្នុង

ន័យនេះយើងបានសិក្សាឃើញថា នៅក្នុងស្នាដៃពុទ្ធនិយមមានបង្ហាញពីព្រលឹងខ្មែរដែលពាក់ព័ន្ធទៅនឹងព្រលឹងទឹកដី ព្រៃព្រឹក្សា និងព្រលឹងវប្បធម៌ជាដើម។ តាមរយៈស្នាដៃរឿងទាំងឡាយដែលជាស្នាដៃនិពន្ធដោយកវីខ្មែរ គឺពិតជាបានឆ្លុះបញ្ចាំងពីទឹកចិត្តស្នេហាជាតិ ស្នេហាទឹកដី ស្នេហាវប្បធម៌ និងកតញ្ញូក៏ដូចជាការប្រយុទ្ធតស៊ូមិនចេះចប់មិនចេះហើយដើម្បីទឹកដីរបស់ខ្លួនជាដើម។ រឿងព្រះជិនវង្សបានបង្ហាញពីការតស៊ូរបស់ព្រះជិនវង្ស ក៏ដូចជាការផ្សងព្រេងនៅក្នុងដំណើរជីវិត ការតស៊ូនៅក្នុងការកសាងខ្លួនពីកុមាររហូតបានក្លាយជាវីរជនមួយរូប។ ព្រះជិនវង្សបានពង្រាយសេចក្ដីស្នេហាដោយកាលៈទេសៈស្របតាមស្ថានការណ៍ជាក់ស្ដែង។ សេចក្ដីស្នេហាភក្ដីភាពដ៏បរិសុទ្ធក៏តំណាងឱ្យព្រលឹងពិតៗរបស់មនុស្សដែលកើតមកហើយរមែងមានសំពាយ ពោលគឺសេចក្ដីស្នេហាកើតមានឡើងតាំងពីពេលដែលគេនៅក្នុងផ្ទៃនៃព្រះមាតាមកម្លេះ។ ស្នេហាគឺជាជីវិត ។ នៅក្នុងន័យនេះស្នាដៃពុទ្ធនិយមបាននាំឱ្យមនុស្សមើលឃើញពីតម្លៃនៃការតស៊ូ ការរស់នៅថាត្រូវតែតស៊ូដើម្បីបុព្វហេតុជាតិមាតុភូមិរបស់ខ្លួន។ នៅលើទឹកដីខ្មែរមានវត្តអារាមជាច្រើនដែលសុទ្ធសឹងតែបានដំណាលពីបុព្វប្រវត្តិរបស់ព្រះពុទ្ធអង្គតាំងពីកុមារភាពរហូតដល់ព្រះអង្គទ្រង់បានត្រាស់ដឹង និងចូលបរិនិព្វាន។ ត្រង់កន្លែងខ្លះក៏មានបង្ហាញពីដំណើរជីវិតរបស់ព្រះពោធិសត្វដែលយោនយកកំណើតជាទន្សាយ ឬសសបណ្ឌិតហើយបានធ្វើជីវិតបរិច្ចាគដើម្បីជួយសង្គ្រោះដល់ឥន្ទ្រព្រាហ្មណ៍ជាដើម។ ត្រង់នេះជាព្រលឹងសាសនាដែលបង្ហាញពីកិរិយាដ៏អស្ចារ្យរបស់ព្រះពោធិសត្វបណ្ឌិតដែលខិតខំបំពេញបារមីគ្រប់បែបយ៉ាងក្នុងគោលបំណងតែមួយគត់គឺត្រាស់ដឹងជាព្រះពុទ្ធនាអនាគត។

នៅក្នុងរឿង ពុទ្ធិសែន នាងកង្រី បានបង្ហាញពីទឹកចិត្តស្វាមីភក្ដិរបស់នាងកង្រីចំពោះព្រះស្វាមី។ ថ្វីបើនាងត្រូវស្លាប់ ប៉ុន្តែដួងចិត្តរបស់នាងគឺមានតែចំពោះពុទ្ធិសែនតែម្នាក់គត់។ នេះជាព្រលឹងភក្ដីភាពដែលមាននៅក្នុងស្នាដៃរឿង។ ដោយឡែកពុទ្ធិសែនវិញក៏ដូចគ្នា ជម្រើសដែលពុទ្ធិសែនត្រូវតែបំពេញក្នុងនាមជាកូនប្រុសគឺការជួយសង្គ្រោះម្ដាយ និងម្ដាយធំឱ្យរួចផុតពីគ្រោះកាចពីទុក្ខវេទនា។ ពីព្រោះថានាងសន្ធមារជាយក្ខិណី ដែលមានគោលបំណងផ្ដាច់ផ្ដិលសម្លាប់ពុទ្ធិសែន និងនាងទាំង១២ ម្លេះហើយពុទ្ធិសែនក្នុងនាមជាកូនត្រូវតែបំពេញកតញ្ញូចំពោះព្រះមាតា។ តាមទស្សនៈរបស់ខ្មែរ កូនណាដែលមិនបានចិញ្ចឹមទំនុកបម្រុងមាតាបិតារបស់ខ្លួន កូននោះរាប់ថាជាកូនអកតញ្ញូ ជាកូនរមិលគុណ ហើយព្រះមិនអាចជួយបានឡើយ។ ពុទ្ធិសែនជាគំរូមួយសម្រាប់ជនានុជនគ្រប់ស្រទាប់វណ្ណៈដែលត្រូវបំពេញកិច្ចតបស្នងសងគុណលោកទាន់លោកនៅមានព្រះជន្ម។ ម្យ៉ាងទស្សនៈរបស់ខ្មែរតែងនិយាយថា«ប្ដីប្រពន្ធរកបានទៀត តែម៉ែឪមានតែមួយគត់នៅក្នុងលោកាយើងនេះ»។ លោកកេង វ៉ាន់សាក់ នៅក្នុងស្នាដៃរបស់លោកធ្លាប់បានពោល

ថា«ជ្រៅហើយធំផងមហាសមុទ្រ គង់គេឆ្លងផុតបានដល់ត្រើយ គុណម្ដាយនេះវិញគ្មានត្រើយឡើយ ជ្រៅហើយធំផងឆ្លងមិនផុត»។ ត្រង់ប្រការនេះយើងអាចចាត់ទុកបានថា ធម៌កតញ្ញូកតវេទីជាព្រលឹងមួយរបស់មនុស្សខ្មែរដែលរំលេចតាមរយៈស្នាដៃអក្សរសិល្ប៍ពុទ្ធនិយម។

ឆ្លងតាមការស្រាយបំភ្លឺខាងលើ ស្នាដៃពុទ្ធនិយមបានបណ្ដុះព្រលឹងជាតិខ្មែរឱ្យប្រជាជនខ្មែរគ្រប់ស្រទាប់វណ្ណៈមានចិត្តស្រឡាញ់ជាតិ សាសនា និងព្រះមហាក្សត្ររបស់ខ្លួនគ្រប់ស្រទាប់វណ្ណៈ។ ដូចនេះនៅពេលមានកលិយុគណាមួយកើតឡើង គឺជនជាតិខ្មែរតែងក្រោកឈរដើម្បីសម្រុកវាយរំដោះជាតិមាតុភូមិរបស់ខ្លួនដូចដែលមាននៅក្នុងពង្សាវតារមហាបុរសខ្មែរមកស្រាប់។

## II.៣.៤.៩- អក្សរសិល្ប៍ពុទ្ធនិយម និងការបណ្ដុះគំនិតវិទ្យាសាស្ត្រ

នៅក្នុងស្នាដៃពុទ្ធនិយមបានបណ្ដុះនូវគំនិតវិទ្យាសាស្ត្រដល់សង្គមខ្មែរនៅសម័យកាលនោះមកម្ល៉េះ ពោលគឺជាស្នាតើវិទ្យាសាស្ត្រដែលកើតឡើងតាមរយៈការស្រមើស្រមៃរបស់កវីនិពន្ធ ប៉ុន្តែបានធ្លាក់ជាប់នូវការចេះដឹងលើការច្នៃប្រឌិតមធ្យោបាយធ្វើដំណើរដល់មនុស្សខ្មែរក៏ដូចជាពិភពលោកទាំងមូល។

តាមរយៈរឿង ហង្ស យន្ត ដែលជាស្នាដៃនិពន្ធរបស់ចៅយមបុណ្យភក្តិ ឧក នាគ្រិស្តសករាជ ១៦៦៨ បានបង្ហាញថា ព្រះបាទអាទិត្យវង្សាសោយរាជ្យនៅនគរក្រុងទេពបុរី មានអគ្គមហេសីព្រះនាម ពិម្ពា ហើយមានព្រះរាជបុត្រមួយព្រះអង្គព្រះនាម សុវណ្ណកុមារ។ ពេលដែលព្រះរាជបុត្រពេញកំលោះ ព្រះបិតាបានចេញព្រះរាជបញ្ជាឱ្យស្ដេច១០១ ប្រទេសដែលជាប្រទេសសមន្តរាជយករាជបុត្រីមកថ្វាយដើម្បីសុវណ្ណកុមាររើសយកនាងណាម្នាក់ដែលមានរូបឆោមល្អធ្វើមហេសី។ ក្នុងបណ្ដាព្រះរាជបុត្រីទាំងនោះសុវណ្ណកុមារពុំសព្វព្រះហឫទ័យដល់តិចណាសោះ។ ជាងទងពីររូបបានធ្វើហង្សយន្តមាសមួយថ្វាយសុវណ្ណកុមារ។ បានហង្សយន្តកាលណា ព្រះរាជកុមារនឹកក្អកស្វែងរកមហេសីដោយព្រះអង្គឯង ហើយក៏ទ្រង់បានទៅសូមលាព្រះមាតាបិតាភរកូតថាៈ យាងទៅរៀនសិល្ប៍។ ក្រោយមកព្រះរាជកុមារបានទៅលបលួចប្រលោមលួងលោមព្រះនាងបទុមកេសរត្រាតែមានព្រះគភ៌។ បិតាព្រះនាងដឹង ក៏ប្រើពេជ្ឈឃាតចាប់ព្រះរាជកុមារ ប៉ុន្តែរាជកុមារក៏បានប្រើឧបាយដោះខ្លួនបាន និងឡើងបញ្ជិះហង្ស យន្ត ចាកចេញជាមួយនឹងព្រះនាងបទុមកេសររត់ចេញទៅ។

តាមរយៈស្នាដៃរឿង ហង្ស យន្ត បានផ្ដល់ចំណេះដឹងវិទ្យាសាស្ត្រដល់មនុស្សខ្មែរឱ្យមានគំនិតច្នៃប្រឌិតខ្ពស់។ ដោយកវីនិពន្ធប៉ិនប្រសប់ក្នុងការរកនឹកត្រិះរិះបង្កើតយានជំនិះដែលកាលនោះ ពិភពលោក

ទាំងមូលពុំទាន់មានការរីកចម្រើនផ្នែកវិទ្យាសាស្ត្រជឿនលឿននៅឡើយផង។ ពោលគឺអ្នកនិពន្ធបានរកនឹកឃានជំនិះដែលអាចបញ្ជាតាមខ្សែញាក់ មានស្លាបដោយគ្រឿងយន្ត។ ម្យ៉ាងវិញទៀត របស់នេះក៏អាចត្រូវភ្លើងឆេះនាំឱ្យគ្រោះថ្នាក់ផងដែរ។ ស្នាដៃរឿង ហង្ស យន្ត ពិតជាវិសេសវិសាលខ្លាំងណាស់។ ព្រោះបានផ្តល់ចំណេះដឹងដល់មនុស្សខ្មែរឱ្យមានគំនិតច្នៃប្រឌិតសម្រាប់ការរស់នៅជាប្រចាំ និងហ៊ានជំនះគ្រប់ឧបសគ្គមិនរាថយ។ បើងាកមកក្នុងសម័យកាលទំនើបនេះវិញ ពិភពលោកសព្វថ្ងៃជឿនលឿនណាស់ គេអាចបង្កើតជាយន្តហោះ ជាផ្កាយរណបដែលអាចហោះហើរ លើអាកាសដឹកអ្នកដំណើរឆ្លងទ្វីបបានយ៉ាងងាយស្រួលជាទីបំផុត។

## II.៣.៣.១០- អក្សរសិល្ប៍ពុទ្ធនិយម និងសន្តិភាពផ្លូវចិត្ត (សីល សមាធិ បញ្ញា)

ស្នាដៃពុទ្ធនិយមនៅសម័យកណ្ដាលប្រៀបបានជាឱសថដ៏ល្អធើតសម្រាប់ព្យាបាលជំងឺផ្លូវចិត្តរបស់ប្រជាជនខ្មែរនៅសម័យកាលនោះ។ ស្នាដៃនោះទៀតសោតបានបណ្តុះស្មារតីអហិង្សា ការបញ្ចប់ទំនាស់ដោយសន្តិវិធីដោយយកគន្លង ឬមាគ៌ាកណ្ដាលនៃព្រះពុទ្ធបរមគ្រូជាគោល។

ស្នាដៃពុទ្ធនិយមតែងរំឭកដល់ត្រៃសរណគមន៍ថា «ពុទ្ធំ សរណំ គច្ឆាមិ ធម្មំ សរណំ គច្ឆាមិ សង្ឃំ សរណំ គច្ឆាមិ » ដែលបានន័យជាសម្រាយថា«ព្រះពុទ្ធ ជាទីពឹង ព្រះធម៌ជាទីពឹង ព្រះសង្ឃជាទីពឹង» ហើយប្រជាជនខ្មែរតែងចងចាំទុក។ យើងជឿជាក់ថា ប្រជាជនខ្មែរនៅសម័យកណ្ដាលបានដក់ជិតទន្ទេញនៅក្នុងចិត្តនៅពេលដែលខ្លួនជួបគ្រោះភ័យជាដើម។ ពោលគឺនៅពេលដែលខ្មែរចួបគ្រោះភ័យ សេចក្ដីសោកទាំងឡាយ ប្រជារាស្ត្រខ្មែរតែងនឹកដល់គុណកែវទាំងបីជាទីពឹងជាទីរំឭកដែលនាំឱ្យចិត្តជ្រះថ្លា ស្ងប់ស្ងាត់ផ្លូវអារម្មណ៍ និងពោរពេញដោយថាមពលផ្លូវចិត្តមានស្មារតីតស៊ូមិនរាថយឡើយ។ ស្នាដៃពុទ្ធនិយមតែងរំឭកដល់គុណកែវទាំងបី គុណមាតាបិតា គុណគ្រូបាអាចារ្យ និងគុណរៀមច្បងដែលសបញ្ជាក់ថាខ្មែរជាជាតិសាសន៍មួយនិយមការដឹងគុណកតញ្ញូកតវេទី និងមានស្មារតីអហិង្សា ប្រកាន់ខ្ជាប់តែអំពើសុចរិតទៀងត្រង់មិនឱ្យប្រាសចាកពីគន្លងឱវាទព្រះពុទ្ធសមណគោត្តមឡើយ។ អក្សរសិល្ប៍ពុទ្ធនិយមសាបព្រោះតែសេចក្ដីល្អ ធម៌អហិង្សា និងស្វែងរកតែសេចក្ដីសុខសន្តិភាពដល់មនុស្សជាតិគ្រប់កាលៈទេសៈដោយមិនចង់ឃើញការបង្ហូរឈាមរវាងជាតិសាសន៍ណាមួយនៅទេ។

នៅក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមក៏បានបង្ហាញពីរាជទសពិធរាជធម៌ ជាពិសេសក្នុងរឿងវិធុរបណ្ឌិត ដំណើររឿងផ្នែកខ្លះបានបង្កប់នូវទសពិធរាជធម៌ ឬច្បាប់សម្រាប់អប់រំមនុស្សក្នុងរាជត្រកូល

ដូចជាច្បាប់ ឬវិន័យសម្រាប់អប់រំបុគ្គលជាអ្នករាជការនៅក្នុងប្រទេសទាំងមូលដែរ។ ទាំងនោះជាលក្ខណៈច្បាប់ដែលជះឥទ្ធិពលមកលើវិស័យច្បាប់រហូតបច្ចុប្បន្ន។ ទោះបីលក្ខណៈច្បាប់នៅក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមពុំមានលក្ខណៈពេញលេញក៏ដោយ ក៏ច្បាប់ទាំងនោះជាគន្លងមួយដែលជាមូលដ្ឋានខ្លះនាំឱ្យលេចឡើងនូវច្បាប់សម្រាប់អប់រំដល់រាជសេវក (មន្ត្រីរាជការ) ប្រតិបត្តិដែរ។ ប្រសិនមន្ត្រីរាជការ ឬបុគ្គលជាអ្នកនៅក្រោមបង្គាប់ ក្រោមការគ្រប់គ្រងបានប្រព្រឹត្តតាមទសពិធរាជធម៌ដែលជាច្បាប់ឬជាវិន័យនេះ បុគ្គលនោះនឹងទទួលបាននូវសេចក្ដីចម្រើនពុំខាន។ អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមបានឆ្លុះបញ្ចាំងពីតម្លៃពុទ្ធិដ៏ទូលំទូលាយក្នុងការដោះស្រាយបញ្ហាទាំងឡាយប្រកបដោយសុទិដ្ឋិឆ្លើយតបនឹងព្រះមហាក្សត្រ និងចំពោះមនុស្សទូទៅ ថែមទាំងបង្ហាញពីភាពកតញ្ញូចំពោះមនុស្សដែលធ្លាប់មានគុណចំពោះខ្លួន និងបង្ហាញពីការប្រឹងប្រែងរបស់ខ្លួនឯងយ៉ាងស្វាហាប់ដែលជាបទពិសោធជាគំរូ ជាការអប់រំដ៏ល្អសម្រាប់មនុស្សទូទៅអនុវត្តក្នុងជីវភាពប្រចាំថ្ងៃ។ ខ្លឹមសារក្នុងស្នាដៃបង្ហាញពីទង្វើអហិង្សា គំនិតអហិង្សា មិនបៀតបៀនអ្នកដទៃចង់បានសន្តិភាពក្នុងសង្គម។ ការបណ្ដុះគំនិតសន្តិភាពតាមរយៈតួអង្គក្នុងរឿងពុទ្ធនិយមនេះ វាជាបទពិសោធ ជាការទូន្មាន និងជាគំរូដល់មនុស្សគ្រប់គ្នាសម្រាប់អនុវត្តក្នុងសង្គមគ្រួសារ ឬសង្គមជាតិទាំងមូលនោះនឹងទទួលបាននូវភាពសុខដុម និងសេចក្ដីចម្រើនមិនខាន។

ឆ្លងតាមការស្រាយបំភ្លឺ ស្នាដៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមជាគំរូមួយក្នុងការអប់រំមនុស្សឱ្យស្រឡាញ់សន្តិភាព ឱ្យស្រឡាញ់អំពើល្អ ឱ្យមានការព្យាយាម ឱ្យចេះស្គាល់គុណ ឱ្យខ្លាចបាប ឱ្យចេះប្រើបញ្ញា ឱ្យចេះពិចារណាលើហេតុនិងផលជាដើម។ ដូច្នេះទើបគេចាត់ទុកអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមនេះជាស្នាដៃអក្សរសិល្ប៍តន្ត្រីរបស់ខ្មែរមួយផ្នែកខាងពុទ្ធសាសនា។ ស្នាដៃទាំងនេះ មានតម្លៃមហាសាលមានប្រយោជន៍យ៉ាងជ្រាលជ្រៅនៅក្នុងមជ្ឈដ្ឋានអ្នកសិក្សាជាតិនិងសង្គមមនុស្សទូទៅ និងជាខឿនយ៉ាងរឹងមាំរបស់វប្បធម៌អរិយធម៌ខ្មែរយើង។

## II.៤- សរុបខ្លឹមសារ

សរុបមក តាមការស្រាយបំភ្លឺខាងលើនេះ យើងបានឃើញថាអក្សរសិល្ប៍ពុទ្ធនិយមពិតជាមានតួនាទីយ៉ាងសំខាន់នៅក្នុងសម័យក្រោយអង្គរប្រាកដមែន។ តួនាទីនេះបានដក់ជិតជាប់នៅក្នុងជីវិតរបស់មនុស្សខ្មែរកាលពីសម័យក្រោយអង្គរ (លង្វែក-ឧដុង្គ) ឱ្យក្រោកឈរតស៊ូជម្នះរាល់ការលំបាកទាំងក្នុងជីវភាពប្រចាំថ្ងៃ និងកាលៈទេសៈនៃការប្រែប្រួលរបស់សង្គម។ ខាងក្រោមនេះជាជាការសង្ខេបឡើងវិញនៃ

តួនាទីអក្សរសិល្ប៍ពុទ្ធនិយមក្នុងសង្គមខ្មែរដូចជា អក្សរសិល្ប៍ពុទ្ធនិយមបានបណ្តុះពុទ្ធិ សាបព្រោះចំណេះដឹងសព្វសារពើដល់មនុស្សខ្មែរឱ្យយល់ដឹងពីទស្សនៈកម្មផល និងជឿទៅលើព្រះពុទ្ធសាសនា។ ក្រៅពីនេះស្នាដៃពុទ្ធនិយមបានអប់រំមនុស្សឱ្យចេះដឹងគុណ និងជឿជាក់លើកម្លាំងផ្ទាល់ខ្លួនស្របដូចពុទ្ធភាសិតថា «អត្តាហិ អត្តនោ នាថោ» បានន័យថា ខ្លួនទីពឹងខ្លួន។ បន្ថែមពីនេះបានអប់រំឱ្យមនុស្សជឿលើបុណ្យបាប ហើយបណ្តុះស្មារតីសន្តិភាពតាមគន្លងព្រះពុទ្ធសាសនា។ ស្នាដៃសម័យក្រោយអង្គរបានបណ្តុះសោភ័ណជីវិតឱ្យខ្មែរស្រឡាញ់ទឹកដី ព្រៃព្រឹក្សា និងជាតិមាតុភូមិរបស់ខ្លួន។ លើសពីនេះបានចូលរួមអភិវឌ្ឍសង្គមលើគ្រប់វិស័យ និងបង្ហាញពីបញ្ហានយោបាយដោយការតស៊ូជម្នះគ្រប់កាលៈទេសៈ។ ជាមួយគ្នានេះផងដែរ កវីនិពន្ធខ្មែរនាសម័យក្រោយអង្គរក៏បានបណ្តុះឱ្យខ្មែរមានគំនិតវិទ្យាសាស្ត្រ មានជំហររឹងមាំ តស៊ូ ខ្លួនទីពឹងខ្លួន មិនព្រមផ្តេកផ្តួលទៅលើព្រេងវាសនានោះឡើយ។ បានសេចក្តីថា ស្នាដៃពុទ្ធនិយមជាបង្អែមក្លែមជីវិត ជាឱសថព្យាបាលផ្លូវចិត្តបានយ៉ាងពូកែស័ក្តិសិទ្ធិនាសម័យកាលនោះ។ ម្យ៉ាងដោយសារតែកវីនិពន្ធខ្មែរយើងសុទ្ធសឹងតែធ្លាប់បានបួសរៀនក្នុងសម្នាក់ព្រះពុទ្ធសាសនា ជារាជកវី ជាព្រះសង្ឃ ជាមន្ត្រី ដែលបានបញ្ចេញស្នាដៃរែកដុះដាលដូចផ្សិតប្រឡងប្រជែងគ្នាផ្នែកខាងអក្សរសាស្ត្រដោយសោមនស្សក្រៃពេករហូតមានខ្មែរចាត់ទុកថាយុគមាសអក្សរសិល្ប៍ទៀតផង។ ត្រង់នេះ យើងជាខ្មែរមានមោទនភាពក្រៃអនេក។

## III- បញ្ចប់សេចក្តី

ឆ្លងតាមការស្រាយបំភ្លឺខាងលើនេះ យើងអាចវាយតម្លៃបានថាប្រធានបទខាងលើនេះពិតជាមានខ្លឹមសារល្អណាស់ ព្រោះបានរំលេចឱ្យយើងស្វែងយល់ និងសង្កេតឃើញយ៉ាងច្បាស់ពីតួនាទីអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ។ ពោលគឺចាប់តាំងពីក្រោយសម័យអង្គរមក សង្គមខ្មែរមានការប្រែប្រួលយ៉ាងខ្លាំងតាំងពីទឹកដី ប្រវត្តិសាស្ត្រ និងសង្គមវប្បធម៌ជាដើម ហើយចាប់ផ្តើមថមថយឥទ្ធិពលរបស់ខ្លួននៅអាស៊ីអាគ្នេយ៍។ ត្រង់នេះយើងបានឃើញថា អក្សរសិល្ប៍ពុទ្ធនិយមជាឱសថព្យាបាលផ្លូវចិត្តរបស់មនុស្សខ្មែរកាលពីសម័យនោះប្រកបដោយប្រសិទ្ធភាព។ អក្សរសិល្ប៍ពុទ្ធនិយមបានចូលរួមកសាងសន្តិភាពសង្គមខ្មែរតាំងពីសម័យបុរាណរហូតមកដល់សម័យបច្ចុប្បន្ន។ ស្នាដៃពុទ្ធនិយមពិតជាមានតួនាទីសំខាន់ណាស់ចាក់គ្រឹះយ៉ាងមាំក្នុងសន្តានចិត្តមនុស្សខ្មែរនាសម័យក្រោយអង្គររហូតដល់បច្ចុប្បន្ន។ ពីព្រោះតាមតាមរយៈអក្សរសិល្ប៍ពុទ្ធនិយមនាំឱ្យមនុស្សខ្មែរជម្រុះចោលនូវអំពើបាប និងត្រងត្រាប់យកតែសេចក្តីល្អបង្កើតតែសេចក្តីសុខគ្រប់ប្រការ។ ដូចនេះក្នុងនាមជាពុទ្ធសាសនិកជនស្វែងយល់ឱ្យបានស៊ីជម្រៅនូវមាគ៌ាព្រះពុទ្ធសាសនាដើម្បីរស់នៅក្រោមម្លប់នៃសន្តិភាពផ្លូវចិត្តគ្រប់ប្រការ។

## ឯកសារពិគ្រោះ

-ឃើង ហុកឌី, ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ, បណ្ណាគារអង្គរ, ឆ្នាំ២០០៣

-ឌឹក គាម, បណ្ឌិតជ័យនន្ទ អ្នកនិពន្ធខ្មែរ, បណ្ណាគារ ងួន ហ៊ួត, ១៩៦៧

-ឈឹម ក្រសេម, សិលាចារឹកនគរវត្ត, ពុទ្ធសាសនបណ្ឌិត្យ, ឆ្នាំ១៩៥៨

-លាងហាប់អាន, សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ, សម័យនគរភ្នំដល់សម័យឧដុង្គ (សតវត្សទី១ ដល់ឆ្នាំ ១៨៥៩), ភ្នំពេញ, ឆ្នាំ ១៩៦៧

-លី ជាមតេង, អក្សរសាស្ត្រខ្មែរ, បណ្ណាគារ ងួន ហ៊ួត, ១៩៦០

-វង់ សុធារ៉ា, សិលាចារឹកនៃប្រទេសកម្ពុជាសម័យកណ្តាល, គ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្ត, ២០១២

-សិក្សាស្នាដៃអក្សរសិល្ប៍ដោយបណ្ណាល័យ សេង សុវណ្ណារ៉ា, ២០២២

-ភាជ ណាង, និក្ខេបបទបណ្ឌិតអក្សរសាស្ត្រ ឯកទេសអក្សរសិល្ប៍ រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១៥

-E. Aymonier, Le Cambodge, Tome III, 1904.

https://www.khsearch.com/qna/15672

https://km.wikipedia.org/wiki/%E%1

https://rac.gov.kh/royal-academy/research/attachments/original/135.pdf?1625998633